# លិខិតទី ២ របស់គ្រីស្ដទូតប៉ូល

# ផ្ញើជូនគ្រីស្ដបរិស័ទនៅក្រុងកូរិនថូស

## ពាក្យជម្រាបសួរ

១ខ្ញុំប៉ូល ដែលព្រះជាម្ចាស់សព្វព្រះហឫទ័យ ១តែងតាំងជាទូតរបស់ព្រះគ្រីស្ដយេស៊ូ ខ្ញុំ និងបងធីម៉ូថេ សូមជម្រាបមកព្រះសហគមន៍របស់ព្រះជាម្ចាស់ នៅក្រុងកូរិនថូ និងជម្រាបមកជនដ៏វិសុទ្ធទាំងអស់នៅស្រុកអាខៃទាំងមូល។ ២សូមព្រះជាម្ចាស់ជាព្រះបិតារបស់យើង និងព្រះអម្ចាស់យេស៊ូគ្រីស្ដប្រោសប្រណី និងប្រទានសេចក្ដីសុខសាន្ដដល់បងប្អូន!

## ពាក្យអរព្រះគុណ

៣សូមអរព្រះគុណព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះយេស៊ូ ជាអម្ចាស់នៃយើង។ ព្រះអង្គជាព្រះបិតា ប្រកបដោយព្រះហឫទ័យមេត្ដាករុណា និងដែលអាចសម្រាលទុក្ខគ្រប់បែបយ៉ាងទាំងអស់។ ៤ព្រះអង្គសម្រាលទុក្ខយើងនៅពេល យើងមានទុក្ខវេទនាសព្វបែបយ៉ាង ដើម្បីឲ្យយើងអាចសម្រាលទុក្ខ អស់អ្នកដែលមានទុក្ខវេទនា ព្រោះព្រះជាម្ចាស់ប្រទានឲ្យយើងផ្ទាល់បានធូរស្បើយ រួចហើយដែរ។ ៥យើងរួមទុក្ខលំបាកផ្សេងៗ ជាមួយព្រះគ្រីស្ដកាន់តែច្រើនយ៉ាងណា យើងក៏បានធូរស្រាលពីទុក្ខដោយសារព្រះគ្រីស្ដកាន់តែច្រើនយ៉ាងនោះដែរ។ ៦បើយើងត្រូវរងទុក្ខវេទនា គឺដើម្បីឲ្យព្រះអង្គសម្រាលទុក្ខ និងសង្គ្រោះបងប្អូន។ បើយើងបានធូរស្បើយក្នុងចិត្តហើយនោះ គឺដើម្បីឲ្យបងប្អូនបានធូរស្បើយក្នុងចិត្ត ធ្វើឲ្យបងប្អូនអាចស៊ូទ្រាំនឹងទុក្ខលំបាកផ្សេងៗ ដូចយើងដែរ។ ៧ដូច្នេះ កាលណាយើងនឹកគិតអំពីបងប្អូន យើងមានសង្ឃឹមយ៉ាងមុតមាំដោយដឹងថា បងប្អូនរងទុក្ខលំបាករួមជាមួយយើងយ៉ាងណា បងប្អូនក៏នឹងបានធូរស្រាលរួមជាមួយយើងយ៉ាងនោះដែរ។

៨យើងចង់ឲ្យបងប្អូនជ្រាបយ៉ាងច្បាស់ អំពីទុក្ខវេទនា ដែលកើតមានដល់យើងនៅស្រុកអាស៊ីនេះ។ យើងបានរងទុក្ខយ៉ាងខ្លាំងហួសពីកម្លាំងដែលយើងអាចទ្រាំបាន រហូតដល់យើងអស់សង្ឃឹមថា នឹងរស់រានមានជីវិតតទៅមុខទៀតផង។ ៩យើងនឹកក្នុងចិត្តថា គេនឹងដាក់ទោសយើងដល់ស្លាប់។ រឿងនេះកើតឡើងដើម្បីកុំឲ្យយើងពឹងផ្អែកលើខ្លួនឯង គឺពឹងផ្អែកលើព្រះជាម្ចាស់ ដែលប្រោសឲ្យមនុស្សស្លាប់មានជីវិតថ្មីឡើង។ ១០ព្រះអង្គបានរំដោះយើងឲ្យរួចផុតពីសេចក្ដីស្លាប់ ដ៏សែនវេទនានេះ ហើយព្រះអង្គក៏នឹងរំដោះយើង តទៅមុខទៀតដែរ។ ពិតមែនហើយ យើងសង្ឃឹមថា ព្រះអង្គ

នឹងរំដោះយើងទៀតជាមិនខាន។ ១១រីឯបងប្អូន
វិញ បងប្អូនក៏បានជួយយើង ដោយអង្វរព្រះជា
ម្ចាស់។ ហេតុនេះ ហើយបានជាព្រះអង្គប្រោស
ប្រណីដល់យើងដោយមានគ្នាច្រើនអង្វរ ហើយ
ក៏នឹងមានគ្នាជាច្រើន នឹងអរព្រះគុណព្រះអង្គ
អំពីយើងដែរ។

## គម្រោងការណ៍របស់គ្រីស្តទូតប៉ូល

១២ស្មារតីយើងធ្វើសាក្សី បញ្ជាក់យើងថា
យើងខ្ពស់មុខ ដោយដឹងថា ឥរិយាបថដែល
យើងប្រកាន់យកក្នុងលោកនេះ ពិតជាត្រឹមត្រូវ
មែន ជាពិសេសរបៀបដែលយើងប្រព្រឹត្តចំពោះ
បងប្អូន ដោយចិត្តស្មោះសរ[ក] និងដោយសុទ្ធចិត្ត
មកពីព្រះជាម្ចាស់។ យើងមិនបានធ្វើតាម
ប្រាជ្ញារបស់លោកីយ៍ទេ គឺធ្វើតាមព្រះហឫទ័យ
ប្រោសប្រណីរបស់ព្រះជាម្ចាស់វិញ។ ១៣យើង
មិនសរសេរសេចក្ដីណាផ្សេងទៀត មកជូនបង
ប្អូន ក្រៅពីសេចក្ដីដែលបងប្អូនអាន និងយល់
ស្រាប់ហើយនោះឡើយ។ ខ្ញុំសង្ឃឹមថា បងប្អូន
មុខជាយល់សេចក្ដីនេះ ជាក់ច្បាស់សព្វគ្រប់មិន
ខាន។ ១៤ដូចបងប្អូនយល់មួយផ្នែករួចមក
ហើយថា យើងបានធ្វើឲ្យបងប្អូនខ្ពស់មុខ
ហើយបងប្អូនក៏នឹងធ្វើឲ្យយើងខ្ពស់មុខ នៅថ្ងៃ
ព្រះអម្ចាស់យេស៊ូនៃយើង ទ្រង់យាងមកនោះ
ដែរ។ ១៥ដោយខ្ញុំមានសេចក្ដីសង្ឃឹមយ៉ាងមុត
មាំនេះហើយ បានជាខ្ញុំមានបំណងចង់មករក
បងប្អូនជាមុនសិន ដើម្បីឲ្យព្រះជាម្ចាស់ប្រោស
ប្រណីបងប្អូនសាជាថ្មីម្ដងទៀត។ ១៦បន្ទាប់មក
ខ្ញុំនឹងចាកចេញពីបងប្អូន ឆ្ពោះទៅស្រុកម៉ាសេ
ដូន ហើយវិលពីស្រុកម៉ាសេដូន មករកបងប្អូន
វិញ ដើម្បីឲ្យបងប្អូនជួយខ្ញុំបន្តដំណើរទៅស្រុក
យូដាទៀត។ ១៧ខ្ញុំសម្រេចចិត្តធ្វើដូច្នេះ តើខ្ញុំ
សម្រេចដោយឥតគិតអ្វីឬ? ឬមួយគម្រោង
ការណ៍របស់ខ្ញុំ កើតមកពីគំនិតលោកីយ៍បានជា
ខ្ញុំនិយាយបាតដៃជាខ្នងដៃ[ខ]ដូច្នេះ? ១៨មានព្រះ
ជាម្ចាស់ជាសាក្សីស្រាប់ហើយថា យើងមិន
និយាយមកកាន់បងប្អូន ដោយពោលពាក្យប្រែ
ប្រួល បាតដៃជាខ្នងដៃនោះទេ ១៩ដ្បិតព្រះគ្រីស្ត
យេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់ ដែល
យើងប្រកាស គឺទាំងខ្ញុំ ទាំងបងប្អូនស៊ីលវ៉ាន
និងបងធីម៉ូថេ ប្រកាសក្នុងចំណោមបងប្អូននោះ
ព្រះអង្គមិនប្រែប្រួល បាតដៃជាខ្នងដៃ សោះ
ឡើយ នៅក្នុងព្រះអង្គមានតែពាក្យសច្ចៈ
ប៉ុណ្ណោះ។ ២០ព្រះគ្រីស្តបានធ្វើឲ្យព្រះបន្ទូល
សន្យាទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ បាន
សម្រេចសព្វគ្រប់ទាំងអស់។ ហេតុនេះហើយ
បានជាយើងពោលពាក្យ«អាម៉ែន» ទៅកាន់
ព្រះជាម្ចាស់ដោយសារព្រះគ្រីស្ត ដើម្បីលើក
តម្កើងសិរីរុងរឿងរបស់ព្រះអង្គ។ ២១គឺព្រះជា
ម្ចាស់ហើយ ដែលប្រទានឲ្យយើង និងបងប្អូន
មានជំនឿខ្ជាប់ខ្ជួនលើព្រះគ្រីស្ត ព្រមទាំងបាន
ចាក់ប្រេង[គ]លើយើងផង ២២ហើយព្រះអង្គក៏
បានដៅសញ្ញាសម្គាល់របស់ព្រះអង្គលើយើង
និង ប្រទានព្រះវិញ្ញាណ មកបញ្ចាំចិត្តយើងផង
ដែរ។

២៣ខ្ញុំសូមជម្រាបបងប្អូន ដោយមានព្រះជា
ម្ចាស់ជាសាក្សីថា ហេតុដែលខ្ញុំមិនទាន់បានទៅ
ក្រុងកូរិនថូនោះ គឺមកពីខ្ញុំយោគយល់ដល់បង
ប្អូន (បើមិនពិតទេ សូមព្រះអង្គផ្ដាច់ជីវិតខ្ញុំចុះ)

។ ២៤ យើងមិនចង់ត្រួតត្រាលើជំនឿរបស់បង
ប្អូនទេ ដ្បិតជំនឿរបស់បងប្អូនមាំមួនរួចស្រេច
ទៅហើយ យើងគ្រាន់តែចង់ធ្វើការរួមជាមួយ
បងប្អូន ដើម្បីឲ្យបងប្អូនមានអំណរតែ
ប៉ុណ្ណោះ។

១ដូច្នេះ ខ្ញុំសម្រេចថា ខ្ញុំមិនវិលមករកបងប្អូន
២វិញ ទាំងព្រួយចិត្តនោះឡើយ។ ២បើខ្ញុំធ្វើឲ្យ
បងប្អូនព្រួយចិត្តទៅហើយ តើនរណានឹងធ្វើឲ្យ
ខ្ញុំសប្បាយក្រៅពីអ្នកដែលខ្ញុំបានធ្វើឲ្យព្រួយចិត្ត
នោះ? ៣សំបុត្រដែលខ្ញុំបានសរសេរមកជូនបង
ប្អូន មានគោលបំណងជៀសវាង កុំឲ្យខ្ញុំព្រួយ
ចិត្តនៅពេលខ្ញុំមកដល់ គឺកុំឲ្យខ្ញុំកើតទុក្ខព្រួយពី
អស់អ្នក ដែលត្រូវធ្វើឲ្យខ្ញុំមានអំណរនោះឡើ
យ។ ខ្ញុំជឿជាក់ថា ពេលខ្ញុំមានអំណរបងប្អូន
ទាំងអស់គ្នា ក៏មានអំណររួមជាមួយខ្ញុំដែរ។ ៤ ខ្ញុំ
សរសេរមកបងប្អូនទាំងតឹងទ្រូងទាំងពិបាកចិត្ត
ទាំងស្រក់ទឹកភ្នែក តែមិនមែនចង់ធ្វើឲ្យបងប្អូន
ព្រួយចិត្តទេ គឺចង់សម្ដែងឲ្យបងប្អូនដឹងអំពី
សេចក្ដីស្រឡាញ់ ដ៏លើសលប់របស់ខ្ញុំចំពោះ
បងប្អូន។

## គ្រីស្ដទូតប៉ូលអត់ទោសឲ្យគេ

៥ប្រសិនបើនរណាម្នាក់ បង្កើតឲ្យមានទុក្ខ
ព្រួយ មិនមែនធ្វើឲ្យខ្ញុំព្រួយចិត្តទេ គឺគាត់ធ្វើឲ្យ
បងប្អូនទាំងអស់ព្រួយចិត្ត ឬយ៉ាងហោចណាស់
ក៏ឲ្យបងប្អូនមួយចំនួនព្រួយចិត្ត (ខ្ញុំថាដូច្នេះ មក
ពីមិនចង់បំផ្លើស)។ ៦បើបងប្អូនភាគច្រើន បាន
ដាក់ទោសមនុស្សបែបនេះល្មមហើយ។ ៧សូម
បងប្អូនអត់ទោសឲ្យគាត់ និងលើកទឹកចិត្តគាត់
ផងទៅ ក្រែងលោគាត់ពិបាកចិត្តខ្លាំងពេក
រហូតដល់ទៅអស់សង្ឃឹម។ ៨ដូច្នេះ ខ្ញុំសូមទូ
ន្មានបងប្អូន ធ្វើយ៉ាងណា បង្ហាញឲ្យឃើញថា
បងប្អូនស្រឡាញ់គាត់។ ៩ ខ្ញុំសរសេរមក ដើម្បី
លចិត្តបងប្អូនមើល ចង់ដឹងថា តើបងប្អូនពិតជា
ស្ដាប់តាមសេចក្ដីទាំងអស់ ដែលខ្ញុំបានបង្គាប់
ឬយ៉ាងណា។ ១០ បើបងប្អូនលើកលែងទោស
ឲ្យអ្នកណា ខ្ញុំក៏លើកលែងទោសឲ្យអ្នកនោះដែ
រ។ ចំពោះខ្លួនខ្ញុំផ្ទាល់ (ប្រសិនបើមានមូល
ហេតុ ដែលខ្ញុំត្រូវអត់ទោសឲ្យនរណាម្នាក់) ខ្ញុំ
លើកលែងទោសឲ្យគេព្រោះតែបងប្អូនដោយខ្ញុំ
យល់ដល់ព្រះគ្រីស្ដ ១១ ដើម្បីកុំឲ្យយើងចាញ់
បោក មារសាតាំងដ្បិតយើងស្គាល់គម្រោងការ
របស់វាស្រាប់ហើយ។

## គ្រីស្ដទូតប៉ូលខ្វល់ខ្វាយក្នុងចិត្ត

១២ពេលខ្ញុំបានទៅដល់ក្រុងត្រូអា ដើម្បី
ប្រកាសដំណឹងល្អរបស់ព្រះគ្រីស្ដ ទោះបីព្រះ
អម្ចាស់បានបើកឱកាស[យ]ឲ្យខ្ញុំក៏ដោយ ក៏ចិត្តខ្ញុំ
ពុំបានស្ងប់ដែរ ព្រោះរកបងទីតូមិនឃើញ។

១៣ហេតុនេះ ខ្ញុំក៏លាបងប្អូននៅក្រុងត្រូអា
ធ្វើដំណើរឆ្ពោះទៅស្រុកម៉ាសេដូន។ ១៤សូមអរ
ព្រះគុណព្រះជាម្ចាស់ ដែលប្រទានឲ្យយើង
មានជ័យជម្នះ រួមជាមួយព្រះគ្រីស្ដជានិច្ច។ ព្រះ
អង្គប្រោសប្រទានឲ្យមនុស្ស នៅគ្រប់ទីកន្លែង
បានស្គាល់ព្រះអង្គ ដោយសារយើងដែលប្រៀប
បីដូចជា ក្លិនក្រអូបសាយគ្រប់ទិសទី!។ ១៥
ចំពោះព្រះជាម្ចាស់ គឺយើងនេះហើយ ជាក្លិន
ក្រអូបរបស់ព្រះគ្រីស្ដ ក្នុងចំណោមអស់អ្នក

ដែលកំពុងតែវិនាស។ ១៦ចំពោះអ្នកដែលត្រូវ
វិនាសយើងជាក្លិននៃសេចក្តីស្លាប់ ដែលនាំឲ្យ
គេស្លាប់។ ចំពោះអ្នកដែលទទួលការសង្គ្រោះ
វិញ យើងជាក្លិននៃជីវិត ដែលនាំឲ្យគេមានជីវិ
ត។ តើនរណាមានសមត្ថភាព អាចនឹងបំពេញ
កិច្ចការនេះបាន? ១៧ យើងមិនមែនជាអ្នកក្លែង
បន្លំព្រះបន្ទូល របស់ព្រះជាម្ចាស់ដូចមនុស្ស
មួយចំនួនធំនោះឡើយ គឺយើងនិយាយដោយ
សុទ្ធចិត្ត ក្នុងនាមព្រះជាម្ចាស់នៅចំពោះព្រះភ័
ក្ត្រព្រះជាម្ចាស់ និងនៅក្នុងអង្គព្រះគ្រីស្ត។

## អ្នកបម្រើព្រះជាម្ចាស់ ក្នុងសម្ព័ន្ធមេត្រីថ្មី

១តើយើងចាប់ផ្តើម តែងតាំងខ្លួនឯង[ង] សាជា
៣ថ្មីទៀតឬ? ឬមួយក៏យើងត្រូវតែធ្វើដូចអ្នកខ្លះ
គឺត្រូវការយកលិខិតតែងតាំងមកជូនបងប្អូន ឬ
សុំលិខិតតែងតាំងពីបងប្អូនវិញ? ២បងប្អូនហ្នឹង
ហើយ ជាលិខិតរបស់យើងជាលិខិតសរសេរ
នៅក្នុងដួងចិត្តរបស់យើង ដែលមនុស្សទាំង
អស់អាចស្គាល់ និងអានបាន។ ៣បងប្អូនពិតជា
លិខិតរបស់ព្រះគ្រីស្តមែន ជាលិខិតដែលព្រះ
អង្គសរសេរផ្ញើមក តាមកិច្ចការដែលយើង
បំពេញ។ លិខិតនេះ មិនមែនសរសេរដោយទឹក
ខ្មៅទេ គឺសរសេរឡើងដោយព្រះវិញ្ញាណរបស់
ព្រះជាម្ចាស់ ដ៏មានព្រះជន្មគង់នៅ មិនមែនជា
លិខិតសរសេរនៅលើផ្ទាំងថ្មទេ គឺសរសេរក្នុង
សាច់ ក្នុងដួងចិត្តរបស់បងប្អូន។

៤យើងមានសេចក្តីទុកចិត្តដ៏មុតមាំ នៅ
ចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់បែបនេះ ក៏ព្រោះតែ
ព្រះគ្រីស្តនេះហើយ។ ៥យើងមិនអាចចាត់ទុក
ថា ខ្លួនយើងមានសមត្ថភាពនឹងធ្វើកិច្ចការអ្វី
មួយ បានដោយខ្លួនយើងផ្ទាល់ឡើយ គឺព្រះជា
ម្ចាស់ឯណោះ ដែលប្រទានឲ្យយើងមានសមត្ថ
ភាពអាចធ្វើបាន។ ៦ព្រះអង្គក៏ប្រទានឲ្យយើង
មានសមត្ថភាព ធ្វើជាអ្នកបម្រើសម្ព័ន្ធមេត្រីដែរ
ជាសម្ព័ន្ធមេត្រីដែលមិនមែនចងឡើងដោយសរ
សេរ ជាលាយលក្ខណ៍អក្សរនោះទេ គឺចងឡើង
ដោយព្រះវិញ្ញាណវិញ ដ្បិតធម្មវិន័យដែលសរ
សេរជាលាយលក្ខណ៍អក្សរ បណ្តាលឲ្យស្លាប់ រី
ឯព្រះវិញ្ញាណវិញ ព្រះអង្គប្រទានជីវិត។

៧ធម្មវិន័យដែលចារឹកលើផ្ទាំងសិលា មាន
សិរីរុងរឿងយ៉ាងខ្លាំង រហូតដល់ទៅជនជាតិអ៊ី
ស្រាអែល មិនអាចសម្លឹងមើលមុខលោកម៉ូសេ
បាន ព្រោះតែសិរីរុងរឿងភ្លឺចាំងពីផ្ទៃមុខលោក
ហើយជាសិរីរុងរឿងស្ថិតនៅតែមួយរយៈ
ប៉ុណ្ណោះ។ ប្រសិនបើមុខងារបម្រើធម្មវិន័យ
ដែលបណ្តាលឲ្យស្លាប់នេះ មានសិរីរុងរឿង
យ៉ាងហ្នឹងទៅហើយ ៨ចុះទម្រាំបើមុខងារបម្រើ
ព្រះវិញ្ញាណវិញ តើនឹងមានសិរីរុងរឿងលើសពី
នេះ យ៉ាងណាទៅទៀត?

៩ប្រសិនបើ មុខងារដែលធ្វើឲ្យមនុស្សត្រូវ
ទទួលទោស មានសិរីរុងរឿងយ៉ាងហ្នឹងទៅ
ហើយ ចុះទម្រាំបើមុខងារដែលធ្វើឲ្យមនុស្ស
បានសុចរិតវិញ តើនឹងរឹតតែមានសិរីរុងរឿង
ប្រសើរលើសលប់យ៉ាងណាទៅទៀត?

១០ ប្រសិនបើយើងប្រៀបធៀបសិរីរុងរឿងពី
សម័យដើម នឹងសិរីរុងរឿងដ៏ខ្ពង់ខ្ពស់បំផុតនា
បច្ចុប្បន្នកាលនេះ យើងនឹងឃើញថា សិរីរុង

រឿងពីដើម ដូចជាមិនរុងរឿងទាល់តែសោះ។
១១ដូច្នេះ ប្រសិនបើអ្វីៗដែលមិនស្ថិតស្ថេរ មាន
សិរីរុងរឿងទៅហើយ ចុះទម្រាំបើអ្វីៗដែលនៅ
ស្ថិតស្ថេរវិញ តើនឹងរឹតតែមានសិរីរុងរឿងយ៉ាង
ណាទៅ?

១២ដោយយើងមានសេចក្ដីសង្ឃឹម យ៉ាង
នេះ យើងក៏មានចិត្តរឹងប៉ឹងឥតរង្កើដែរ។

១៣យើងមិនធ្វើដូចលោកម៉ូសេទេ គឺលោក
បានយកស្បៃមកបាំងមុខ កុំឲ្យជនជាតិអ៊ីស្រា
អែល សម្លឹងមើលរស្មីដែលមិនស្ថិតស្ថេរនោះ
ចេញបាត់ពីផ្ទៃមុខលោក។ ១៤ប៉ុន្តែ គំនិតរបស់
ជនជាតិអ៊ីស្រាអែល នៅងងឹតសូន្យ ដ្បិតរហូត
មកទល់សព្វថ្ងៃ ពេលគេអានគម្ពីរសម្ពន្ធមេត្រី
ចាស់ ស្បៃដដែលនោះ នៅបាំងគំនិតរបស់គេ។
ស្បៃនៅបាំងគេដដែល លុះដល់គេចូលរួម
ជាមួយព្រះគ្រីស្ត ទើបស្បៃនោះ រសាត់បាត់
ទៅ។ ១៥មកទល់សព្វថ្ងៃនេះ ពេលគេអានគម្ពីរ
របស់លោកម៉ូសេមានស្បៃមួយនៅបាំងចិត្តគេ
មិនឲ្យយល់ ១៦ក៏ប៉ុន្តែ «នៅពេលគេបែរចិត្ត
គំនិតរកព្រះអម្ចាស់ ស្បៃនោះចេញពីគេបាត់
ទៅ»[ច] ១៧ដ្បិតព្រះអម្ចាស់ជាព្រះវិញ្ញាណ។ នៅ
ទីណា មានព្រះវិញ្ញាណរបស់ព្រះអម្ចាស់នៅទី
នោះ ក៏មានសេរីភាពដែរ។ ១៨យើងទាំងអស់គ្នា
ដែលគ្មានស្បៃនៅបាំងមុខ យើងបញ្ចេញសិរី
រុងរឿងរបស់ព្រះអម្ចាស់ ដែលចាំងមកលើយើង
ហើយយើងនឹងផ្លាស់ប្រែឲ្យបានដូចព្រះអង្គ គឺ
មានសិរីរុងរឿងកាន់តែភ្លឺឡើងៗ។ នេះហើយ
ជាស្នាព្រះហស្តរបស់ព្រះវិញ្ញាណ នៃព្រះ
អម្ចាស់[ឆ]។

## ព្រះគ្រីស្តគាំពារអ្នកប្រកាសដំណឹងល្អ

១បើព្រះជាម្ចាស់មានព្រះហឫទ័យ មេត្តា
ករុណា ប្រគល់មុខងារនេះមកឲ្យយើង យើង
មិនត្រូវបាក់ទឹកចិត្តឡើយ។
២យើងបដិសេធ មិនប្រព្រឹត្តការលួចលាក់
ណាដែលគួរឲ្យអៀនខ្មាសនោះទេ ហើយក៏មិន
បោកបញ្ឆោតគេ ឬក្លែងបន្លំព្រះបន្ទូលរបស់ព្រះ
ជាម្ចាស់ដែរ។ ផ្ទុយទៅវិញ យើងបង្ហាញឲ្យ
មនុស្សលោកស្គាល់សេចក្ដីពិត ទាំងនាំគេឲ្យ
ទុកចិត្តលើយើងនៅចំពោះ ព្រះភក្ត្រព្រះជាម្ចា
ស់។ ៣ប្រសិនបើអត្ថន័យនៃដំណឹងល្អ នៅតែ
លាក់កំបាំង គឺលាក់កំបាំងតែចំពោះអស់អ្នក
ដែលត្រូវវិនាសប៉ុណ្ណោះ។

៤ជាអ្នកមិនជឿ ដែលត្រូវព្រះនៃលោកីយ៍
នេះធ្វើឲ្យចិត្តគំនិតរបស់គេទៅជាងងឹត មិនឲ្យ
គេឃើញពន្លឺរស្មីដ៏រុងរឿង នៃដំណឹងល្អរបស់
ព្រះគ្រីស្ត ជាតំណាង[ជ]របស់ព្រះជាម្ចាស់នោះ
ឡើយ។ ៥យើងមិនប្រកាសអំពីខ្លួនយើងទេ គឺ
យើងប្រកាសអំពីព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់
ហើយយើងដាក់ខ្លួនជាអ្នកបម្រើបងប្អូន ព្រោះ
តែព្រះយេស៊ូនេះហើយ។ ៦ព្រះជាម្ចាស់ដែល
មានព្រះបន្ទូលថា៖ «ចូរឲ្យមានពន្លឺភ្លឺចេញពី
ងងឹត!» ព្រះអង្គក៏បានបំភ្លឺចិត្តគំនិតរបស់យើង
ឲ្យស្គាល់យ៉ាងច្បាស់ នូវសិរីរុងរឿងរបស់ព្រះជា
ម្ចាស់ ដែលភ្លឺចាំងពីព្រះភ័ក្ត្ររបស់ព្រះគ្រីស្តដែ
រ។

៧យើងមានមុខងារដ៏ប្រសើរ[ឈ]នេះ ប្រៀប
បីដូចជា ឆ្នាំងដីដែលមានកំណប់មាសនៅខាង
ក្នុង ដើម្បីឲ្យមនុស្សលោកឃើញថាឫទ្ធានុភាព

ដ៏ប្រសើរខ្ពង់ខ្ពស់នេះ ជាឫទ្ធានុភាពរបស់ព្រះ
ជាម្ចាស់ មិនមែនជារបស់យើងទេ។ ៨ គេសង្កត់
សង្កិនយើងគ្រប់យ៉ាងមែន តែយើងមិនភ័យ
បារម្ភអ្វីឡើយ យើងទ័លច្រកមែន តែយើងនៅ
តែទៅមុខរួច ៩ គេបៀតបៀនយើងមែន តែព្រះ
ជាម្ចាស់មិនបោះបង់យើងចោលឡើយ គេវាយ
ដំយើងមែន តែយើងមិនស្លាប់បាត់បង់ជីវិតឡើ
យ។ ១០ ក្នុងរូបកាយយើង យើងផ្ទុកសេចក្ដីឈឺ
ចាប់[ញ]របស់ព្រះយេស៊ូជានិច្ច ដើម្បីឲ្យគេឃើញ
ព្រះជន្មរបស់ព្រះអង្គ នៅក្នុងរូបកាយយើង។
១១ ព្រោះតែព្រះយេស៊ូ យើងដែលកំពុងរស់
តែងតែប្រឈមមុខទល់នឹងសេចក្ដីស្លាប់ជានិច្ច
ដើម្បីឲ្យគេឃើញព្រះជន្មរបស់ព្រះអង្គ នៅក្នុង
រូបកាយយើង ដែលរមែងតែងតែស្លាប់។
១២ ដូច្នេះ សេចក្ដីស្លាប់ចេះតែយាយីយើង រីឯ
បងប្អូនវិញ បងប្អូនចេះតែមានជីវិតចម្រើនឡើ
ង។

១៣ ដោយយើងមានវិញ្ញាណ ដែលនាំឲ្យជឿ
ស្របតាមសេចក្ដីដែលមានចែងទុកថា «ខ្ញុំជឿ
ហេតុនេះហើយ បានជាខ្ញុំនិយាយ»[ដ] យើងក៏
ជឿដែរ ហេតុនេះហើយបានជាយើងនិយាយ។
១៤ យើងដឹងថា ព្រះអង្គបានប្រោសព្រះអម្ចាស់
យេស៊ូ ឲ្យមានព្រះជន្មថ្មីដ៏រុងរឿង ទ្រង់ក៏នឹង
ប្រោសយើងឲ្យមានជីវិតថ្មីរួមជាមួយព្រះយេស៊ូ
ដែរ ព្រមទាំងនាំយើងទៅក្បែរព្រះអង្គ រួម
ជាមួយបងប្អូនថែមទៀតផង។ ១៥ ហេតុការណ៍
ទាំងនេះកើតឡើងជាប្រយោជន៍ដល់បងប្អូន គឺ
ឲ្យព្រះជាម្ចាស់ប្រោសប្រណីបងប្អូន កាន់តែ
ច្រើនឡើងៗ ដើម្បីឲ្យមានគ្នាមួយចំនួនធំ អរ
ព្រះគុណព្រះជាម្ចាស់កាន់តែច្រើនឡើង និង
លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។

## លំនៅដែលស្ថិតស្ថេរអស់កល្បជានិច្ច

១៦ ហេតុនេះហើយ បានជាយើងមិនបាក់
ទឹកចិត្តឡើយ ទោះបីរូបកាយរបស់យើងចេះតែ
ទ្រុឌទ្រោមទៅៗក៏ដោយ ក៏ជម្រៅចិត្តយើង[ឋ]
កាន់តែចម្រើនឡើងជារៀងរាល់ថ្ងៃដែរ ១៧ ដ្បិត
ទុក្ខលំបាកបន្តិចបន្តួច ដែលយើងជួបប្រទះម្ដង
ម្កាលនោះ ធ្វើឲ្យយើងមានសិរីរុងរឿងដ៏ប្រសើរ
លើសលប់ ជាសិរីរុងរឿងនៅស្ថិតស្ថេរអស់
កល្បជានិច្ច ដែលរកអ្វីមកប្រៀបផ្ទឹមពុំបាន។
១៨ ដូច្នេះយើងមិនចាប់អារម្មណ៍នឹងអ្វីៗ ដែល
ភ្នែកមើលឃើញឡើយ គឺយើងចាប់អារម្មណ៍
នឹងអ្វីៗដែលភ្នែកមើលមិនឃើញនោះវិញ ដ្បិត
អ្វីៗដែលភ្នែកមើលឃើញ នៅស្ថិតស្ថេរតែមួយ
រយៈប៉ុណ្ណោះ តែអ្វីៗដែលភ្នែកមើលមិនឃើញ
នៅស្ថិតស្ថេរអស់កល្បជានិច្ច។

១ យើងដឹងហើយថា រូបកាយរបស់យើងនៅ
៥ លើផែនដីនេះ ប្រៀបដូចជាជម្រកមួយ ដែល
ត្រូវរលាយសូន្យទៅ តែយើងមានវិមានមួយ
នៅស្ថានបរមសុខជាលំនៅស្ថិតស្ថេរអស់កល្ប
ជានិច្ច ដែលពុំមែនជាស្នាដៃរបស់មនុស្សឡើយ
គឺជាស្នាព្រះហស្ដរបស់ព្រះជាម្ចាស់។ ២ ឥឡូវ
នេះ យើងតែងតែត្អូញត្អែរសង្វាតចង់បានរូប
កាយនៃស្ថានបរមសុខ មកគ្របពីលើរូបកាយ
នេះថែមទៀត ៣ គឺឲ្យតែបានរូបកាយថ្មីប្រសើរ
ជាជាងនៅខ្លួនទទេ គ្មានរូបកាយ។
៤ ពេលស្ថិតនៅក្នុងរូបកាយនេះ នៅឡើយ

យើងតែងតែថ្ងូញថ្ងែរ និងពិបាកចិត្ត។ យើងមិន
ចង់ដោះរូបកាយនេះចោលទេ គឺចង់ពាក់រូប
កាយថ្មីពីលើថែមទៀត ដើម្បីឲ្យជីវិតលេប
បំបាត់នូវអ្វីៗ ដែលរមែងតែងតែស្លាប់នេះ។
៥ ព្រះជាម្ចាស់ផ្ទាល់ បានតម្រូវឲ្យយើងផ្លាស់ប្រែ
ដូច្នេះ ព្រះអង្គក៏បានប្រទានព្រះវិញ្ញាណមក
បញ្ចាំចិត្តយើងផងដែរ។

៦ ដូច្នេះ យើងមានចិត្តក្លាហានជានិច្ច។
យើងដឹងថាដរាបណាយើងស្ថិតនៅក្នុងរូបកាយ
នេះ យើងឃ្លាតឆ្ងាយពីព្រះអម្ចាស់។ ៧ដ្បិត
យើងធ្វើដំណើរ ដោយមានជំនឿ មិនមែន
ដោយមើលឃើញនោះទេ។ ៨យើងមានចិត្ត
ក្លាហាន យើងចូលចិត្តឃ្លាតឆ្ងាយពីរូបកាយនេះ
ហើយទៅនៅជិតព្រះអម្ចាស់ ប្រសើរជាង។
៩ ទោះបីយើងស្ថិតនៅក្នុងរូបកាយនេះ ឬក៏ត្រូវ
ឃ្លាតឆ្ងាយពីរូបកាយនេះក្ដី យើងមានបំណងធ្វើ
យ៉ាងណាឲ្យតែបានគាប់ព្រះហឫទ័យព្រះអង្គ
១០ ដ្បិតយើងទាំងអស់គ្នា នឹងត្រូវទៅឈរនៅ
មុខទីកាត់ក្ដីរបស់ព្រះគ្រីស្ដ ដើម្បីឲ្យម្នាក់ៗ
ទទួលផលតាមអំពើដែលខ្លួនបានប្រព្រឹត្ត
ទោះបីជាអំពើនោះល្អ ឬអាក្រក់ក្ដី កាលពីនៅ
រស់ក្នុងរូបកាយនេះនៅឡើយ។

## មុខងារសម្រុះសម្រួល

១១ ដោយយើងបានស្គាល់ ការគោរពកោត
ខ្លាចព្រះជាម្ចាស់ហើយ យើងក៏ខិតខំណែនាំ
មនុស្សលោកឲ្យជឿដែរ។ព្រះជាម្ចាស់ស្គាល់
ចិត្តយើង (ខ្ញុំសង្ឃឹមថា នៅក្នុងស្មារតីរបស់បង
ប្អូន បងប្អូនក៏ស្គាល់ចិត្តយើងដែរ)។ ១២យើង
មិនតែងតាំងខ្លួនឯង នៅចំពោះមុខបងប្អូនសា
ជាថ្មីទៀតទេ តែយើងជូនឱកាសឲ្យបងប្អូនបាន
ខ្ពស់មុខ ព្រោះតែយើងវិញ ដើម្បីឲ្យបងប្អូនអាច
ឆ្លើយតបនឹងអស់អ្នកដែលអួតខ្លួនតែពីអ្វីៗ នៅ
ខាងក្រៅ ហើយមិនគិតពីអ្វីៗក្នុងចិត្តទេ។

១៣ ប្រសិនបើគេថា យើងជាមនុស្សវង្វេង
ស្មារតី នោះយើងវង្វេងស្មារតីព្រោះតែព្រះជា
ម្ចាស់ ហើយប្រសិនបើគេថា យើងជាមនុស្ស
ដឹងខុសត្រូវនោះ យើងដឹងខុសត្រូវព្រោះតែបង
ប្អូន ១៤ដ្បិតព្រះហឫទ័យស្រឡាញ់របស់ព្រះគ្រី
ស្ដជំរុញយើង ដោយយើងយល់ឃើញថា បើ
មនុស្សម្នាក់ស្លាប់ សម្រាប់មនុស្សទាំងអស់នោះ
មនុស្សទាំងអស់ក៏ដូចជាស្លាប់ដែរ។ ១៥ព្រះអង្គ
សោយទិវង្គត សម្រាប់មនុស្សទាំងអស់ ដើម្បី
ឲ្យអស់អ្នកដែលមានជីវិត លែងរស់សម្រាប់ខ្លួន
ឯងទៀតហើយ គឺរស់សម្រាប់ព្រះអង្គ ដែល
បានសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿង
សម្រាប់គេ។ ១៦ ដូច្នេះ ពីពេលនេះតទៅយើង
ឈប់រាប់នរណាម្នាក់ តាមរបៀបលោកីយ៍ទៀត
ហើយ ទោះបីយើងធ្លាប់ស្គាល់ព្រះគ្រីស្ដ កាល
ព្រះអង្គនៅជាមួយមនុស្សធម្មតាក៏ដោយ ក៏
ឥឡូវនេះ យើងមិនស្គាល់ព្រះអង្គតាមរបៀប
មុនទៀតឡើយ។ ១៧ប្រសិនបើអ្នកណាម្នាក់
នៅរួមជាមួយព្រះគ្រីស្ដ អ្នកនោះបានកើតជាថ្មី
អ្វីៗពីអតីតកាលបានកន្លងផុតទៅ ហើយអ្វីៗ
ទាំងអស់បានប្រែមកជាថ្មីវិញ។ ១៨ការទាំងនេះ
កើតមកពីព្រះជាម្ចាស់ ដែលសម្រុះសម្រួល
យើងឲ្យជានានឹងព្រះអង្គវិញ ដោយសារព្រះគ្រី
ស្ដ ហើយប្រទានឲ្យយើងមានមុខងារ

សម្រុះសម្រួលមនុស្សម្នា ឲ្យជានានឹងព្រះអង្គ
វិញដែរ។

១៩នៅក្នុងព្រះគ្រីស្ត ព្រះជាម្ចាស់បានសម្រុះ
សម្រួលមនុស្សលោក ឲ្យជានានឹងព្រះអង្គ
ដោយមិនប្រកាន់ទោសគេឡើយ។ ព្រះអង្គក៏
ដាក់ព្រះបន្ទូលនៃការសម្រុះសម្រួលនេះ មក
ក្នុងយើងដែរ។ ២០ដូច្នេះ យើងជាទូតរបស់ព្រះ
គ្រីស្ត គឺដូចជាព្រះជាម្ចាស់មានព្រះបន្ទូលដាស់
តឿនបងប្អូន ដោយសារយើងដែរ។ យើងសូម
អង្វរបងប្អូនក្នុងព្រះនាមព្រះគ្រីស្តថា ទុកឲ្យព្រះ
ជាម្ចាស់សម្រុះសម្រួលបងប្អូន ឲ្យជានា នឹង
ព្រះអង្គវិញទៅ។ ២១ព្រះគ្រីស្តគ្មានបាប
ទាល់តែសោះ តែព្រះជាម្ចាស់បានធ្វើឲ្យព្រះអង្គ
ទៅជាតួបាបសម្រាប់យើង ដើម្បីប្រោសយើង
ឲ្យបានសុចរិតរួមជាមួយព្រះគ្រីស្តដែរ។

១ដោយយើងធ្វើការ រួមជាមួយព្រះជាម្ចាស់
៦យើងសូមទូន្មានបងប្អូនថា កុំទទួលការ
ប្រោសប្រណីរបស់ព្រះអង្គ យកមកទុកចោល
ជាអសារឥតការឡើយ ២ដ្បិត ព្រះជាម្ចាស់
មានព្រះបន្ទូលថា៖ *«យើងបានឆ្លើយតបមក
អ្នក នៅគ្រាណាដែលយើងគាប់ចិត្ត យើងបាន
ជួយអ្នកនៅថ្ងៃណា ដែលយើងសង្គ្រោះមនុស្ស
លោក»*[ឱ]។

គ្រាដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ គឺ
ឥឡូវនេះហើយ! គឺឥឡូវនេះហើយ ជាថ្ងៃដែល
ព្រះជាម្ចាស់សង្គ្រោះមនុស្សលោក!

៣យើងមិនចង់ឲ្យកើតមានរឿងអ្វីមួយ ដែល
បណ្ដាលឲ្យនរណាម្នាក់ ជំពប់ចិត្តបាត់ជំនឿ
ឡើយ ដើម្បីកុំឲ្យគេបន្ទោសមុខងាររបស់យើ
ង។ ៤ផ្ទុយទៅវិញ យើងតាំងខ្លួនជាអ្នកបម្រើ
របស់ព្រះជាម្ចាស់ ក្នុងគ្រប់កាលៈទេសៈទាំង
អស់ ដោយស៊ូទ្រាំយ៉ាងខ្លាំង ដោយជួបនឹងទុក្ខ
លំបាក ខ្វះខាត ភ័យបារម្ភ ៥គេវាយដំយើង គេ
ឃុំឃាំងយើង គេលើកគ្នាមកប្រឆាំងនឹងយើង។
យើងធ្វើការធ្ងន់អត់ងងុយ អត់អាហារ។ ៦យើង
តាំងខ្លួនជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ដោយ
មានចិត្តបរិសុទ្ធ ដោយស្គាល់ព្រះជាម្ចាស់
ដោយមានចិត្តអត់ធ្មត់ ចិត្តសប្បុរស ដោយព្រះ
វិញ្ញាណដ៏វិសុទ្ធ ដោយមានចិត្តស្រឡាញ់ឥត
ពុតត្បុត ៧ដោយប្រកាសសេចក្ដីពិត ដោយ
ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ យើងយក
សេចក្ដីសុចរិតធ្វើជាអាវុធ វាយប្រយុទ្ធ និង
ការពារ ៨ទាំងទ្រាំទ្រនៅពេលគេគោរព យើងក្ដី
បន្ទាបបន្ថោកយើងក្ដី នៅពេលគេនិយាយ
អាក្រក់ ឬនិយាយល្អពីយើងក្ដី។ គេចាត់ទុក
យើងថា ជាជនបោកប្រាស់ តែយើងជាមនុស្ស
ទៀងត្រង់។ ៩គេចាត់ទុកយើង ដូចជាអ្នកដែល
គ្មាននរណាស្គាល់ តែមនុស្សទាំងអស់ស្គាល់
យើងយ៉ាងច្បាស់។ គេចាត់ទុកយើងដូចជា
មនុស្សហៀបនឹងស្លាប់ តែយើងពិតជានៅមាន
ជីវិត។ គេធ្វើទារុណកម្មយើង តែយើងគ្មាន
ទោសដល់ស្លាប់ទេ។

១០គេធ្វើឲ្យយើងមានទុក្ខព្រួយ តែយើង
សប្បាយចិត្តជានិច្ច។ យើងដូចជាអ្នកក្រ តែ
យើងបានធ្វើឲ្យមនុស្សជាច្រើន ទៅជាអ្នកមាន
យើងដូចជាគ្មានអ្វីសោះ តែយើងមានសព្វគ្រប់
ទាំងអស់វិញ។

១១បងប្អូនក្រុងកូរិនថូ! យើងនិយាយមកបង

ប្អូនដោយស្មោះអស់ពីចិត្ត ឥតលាក់លៀមអ្វី
ឡើយ ១២យើងមិនចង្អៀតចង្អល់ចំពោះបងប្អូន
ទេ គឺបងប្អូនទេតើដែលមានចិត្តចង្អៀតចង្អល់។
១៣ខ្ញុំនិយាយមកបងប្អូនដូចនិយាយទៅកាន់កូន
ចៅរបស់ខ្លួន ដូច្នេះសូមបងប្អូនឲ្យមានចិត្ត
ទូលាយជាមួយយើង ដូចជាយើងមានចិត្ត
ទូលាយចំពោះបងប្អូនដែរ។

## ការញែកខ្លួនចេញពីអំពើអាក្រក់

១៤សូមកុំសេពគប់ ជាមួយអ្នកមិនជឿឡើ
យ។ តើសេចក្ដីសុចរិតនិងសេចក្ដីទុច្ចរិត រួម
ជាមួយគ្នាដូចម្ដេចកើត? តើពន្លឺនិងភាពងងឹត
រួបរួមគ្នាដូចម្ដេចកើត? ១៥តើពន្លឺព្រះគ្រីស្ដ និង
មារសាតាំងចុះសម្រុងគ្នាបានទេ? តើអ្នកជឿ
និងអ្នកមិនជឿ មានទំនាក់ទំនងជាមួយគ្នាយ៉ាង
ណា? ១៦តើព្រះវិហាររបស់ព្រះជាម្ចាស់ និងព្រះ
ក្លែងក្លាយចូលគ្នាបានទេ? យើងទាំងអស់គ្នាជា
ព្រះវិហាររបស់ព្រះជាម្ចាស់ ដ៏មានព្រះជន្មគង់
នៅ ដូចព្រះអង្គមានព្រះបន្ទូលថា៖ «យើងនឹង
ស្ថិតនៅជាមួយពួកគេ ព្រមទាំងរស់នៅជាមួយ
គេដែរ។ យើងនឹងទៅជាព្រះរបស់គេហើយ គេ
នឹងទៅជាប្រជារាស្ត្ររបស់យើង»[ឈ]។

១៧ហេតុនេះហើយ បានជាព្រះអម្ចាស់មាន
ព្រះបន្ទូលថា៖ «ចូរចេញពីចំណោមអ្នកទាំង
នោះ ហើយញែកខ្លួនចេញឲ្យដាច់ពីពួកគេ កុំ
ប៉ះពាល់អ្វីដែលមិនបរិសុទ្ធឡើយ នោះយើង
នឹងទទួលអ្នករាល់គ្នា ១៨យើងនឹងទៅជាឪពុក
របស់អ្នករាល់គ្នា ហើយអ្នករាល់គ្នា ក៏ទៅជាកូន
ប្រុសកូនស្រីរបស់យើងដែរ»។ នេះជាព្រះ
បន្ទូលរបស់ព្រះអម្ចាស់ ដ៏មានឫទ្ធានុភាពខ្ពង់
ខ្ពស់បំផុត[ណ]។

១បងប្អូនជាទីស្រឡាញ់! បើយើងបានទទួល
៧ព្រះបន្ទូលសន្យា ដ៏អស្ចារ្យយ៉ាងនេះហើយ
យើងត្រូវជម្រះខ្លួនឲ្យបានបរិសុទ្ធ ចាកផុតពី
សៅហ្មងគ្រប់យ៉ាង ទាំងខាងរូបកាយ ទាំងខាង
វិញ្ញាណ ដើម្បីឲ្យបានវិសុទ្ធទាំងស្រុង ដោយ
គោរពកោតខ្លាចព្រះជាម្ចាស់។

## អំណរសប្បាយរបស់គ្រីស្ដទូតប៉ូល

២សូមបងប្អូនយល់ចិត្តយើងផង! យើងពុំ
បានបោកប្រាស់នរណា ពុំបានធ្វើឲ្យនរណា
ហិនហោច ឬក៏កេងប្រវ័ញ្ចនរណាម្នាក់ឡើយ។
៣ខ្ញុំនិយាយដូច្នេះ មិនមែនចង់ចោទប្រកាន់បង
ប្អូនទេ ដ្បិតខ្ញុំបានជម្រាបបងប្អូនរួចស្រេច
ហើយថា យើងស្រឡាញ់បងប្អូន និង ស៊ូស្លាប់
រស់ជាមួយបងប្អូនជានិច្ច។ ៤ខ្ញុំទុកចិត្តលើបង
ប្អូនយ៉ាងខ្លាំង ហើយខ្ញុំបានខ្ពស់មុខ ព្រោះតែ
បងប្អូនដែរ។ ទោះបីយើងកំពុងតែរងទុក្ខវេទនា
ខ្លាំងយ៉ាងនេះក៏ដោយ ខ្ញុំក៏បានធូរស្បើយក្នុង
ចិត្តយ៉ាងច្រើន ព្រមទាំងមានអំណរសប្បាយ
ពន់ប្រមាណ។ ៥តាំងពីយើងបានទៅដល់ស្រុក
ម៉ាសេដូន យើងពុំដែលបានសម្រាក តាម
លោកីយ៍ឡើយ។ យើងបានរងទុក្ខវេទនាសព្វ
បែបយ៉ាង គឺផ្នែកខាងក្រៅ គេធ្វើបាបយើង
ហើយនៅខាងក្នុងចិត្ត យើងចេះតែបារម្ភ។ ៦ក៏
ប៉ុន្ដែ ព្រះជាម្ចាស់ដែលតែងតែ សម្រាលទុក្ខអ្នក
ទន់ទាប ទ្រង់បានសម្រាលទុក្ខយើង ដោយបង
ទីតូទៅដល់។ ៧យើងធូរចិត្ត មិនមែនត្រឹមតែ

បានបងទីតូទៅដល់ប៉ុណ្ណោះទេ គឺមកពីបងប្អូនបានសម្រាលទុក្ខគាត់ផងដែរ។ គាត់នាំដំណឹងមកថា បងប្អូនមានចិត្តចង់ជួបខ្ញុំយ៉ាងខ្លាំង បងប្អូនបង្ហូរទឹកភ្នែក ព្រមទាំងឈឺឆ្អាលនឹងខ្ញុំ ជាហេតុធ្វើឲ្យខ្ញុំមានអំណររឹតតែខ្លាំងឡើងថែមទៀតផង។

៨ប្រសិនបើ សេចក្ដីដែលខ្ញុំសរសេរក្នុងសំបុត្រនោះ បានធ្វើឲ្យបងប្អូនព្រួយចិត្ត ក៏ខ្ញុំស្ដាយក្រោយ (ដ្បិតខ្ញុំយល់ឃើញថា សំបុត្រនោះនាំឲ្យបងប្អូនព្រួយចិត្តមួយគ្រាមែន) ៩ក៏នៅពេលនេះ ខ្ញុំសប្បាយចិត្តមិនមែនមកពីបងប្អូនព្រួយចិត្តគំនិត ដ្បិតបងប្អូនព្រួយចិត្តដូច្នេះស្របតាមព្រះជាម្ចាស់។ ហេតុនេះយើងពុំបានធ្វើឲ្យបងប្អូនខូចខាតអ្វីឡើយ។

១០តាមពិត ទុក្ខព្រួយស្របតាមព្រះជាម្ចាស់បែបនេះ តែងតែនាំឲ្យប្រែចិត្តគំនិត ដើម្បីទទួលការសង្គ្រោះ ហើយយើងមិនស្ដាយក្រោយឡើយ។ រីឯទុក្ខព្រួយតាមបែបលោកីយ៍ តែងតែនាំឲ្យស្លាប់វិញ។ ១១សូមគិតមើល ទុក្ខព្រួយដែលស្របតាមព្រះជាម្ចាស់ដូច្នេះ មានផលប្រយោជន៍ចំពោះបងប្អូនយ៉ាងណា គឺបងប្អូនមានចិត្តខ្នះខ្នែង ហើយលើសពីនេះទៅទៀតបងប្អូនចេះសុំទោស ទាស់ចិត្តនឹងអំពើអាក្រក់ មានចិត្តគោរពកោតខ្លាច មានចិត្តប៉ងប្រាថ្នាយ៉ាងខ្លាំងមានចិត្តឈឺឆ្អាល ហើយបងប្អូនក៏ចេះដាក់ទោសអ្នកប្រព្រឹត្តអំពើអាក្រក់ដែរ។ ការទាំងនេះបង្ហាញឲ្យឃើញថា បងប្អូនគ្មានសៅហ្មងអ្វីទាំងអស់ក្នុងរឿងនេះ។

១២ដូច្នេះ ហេតុដែលខ្ញុំសរសេរមកបងប្អូនមិនមែនមកពីគិតដល់អ្នកប្រព្រឹត្តអាក្រក់ ឬគិតដល់អ្នកដែលរងនូវអំពើអាក្រក់នោះឡើយ ខ្ញុំសរសេរមក ដើម្បីឲ្យបងប្អូនមានឱកាសបង្ហាញទឹកចិត្តខ្នះខ្នែងរបស់បងប្អូនចំពោះយើង នៅមុខព្រះជាម្ចាស់។ ១៣ការនេះហើយ ដែលបានសម្រាលទុក្ខយើង។ ប៉ុន្តែ លើសពីនេះ យើងក៏មានអំណររឹតតែខ្លាំងថែមទៀត ដោយឃើញបងទីតូមានអំណរសប្បាយ ព្រោះបងប្អូនទាំងអស់គ្នាបានជួយគាត់ឲ្យស្ងប់ចិត្ត លែងព្រួយបារម្ភ។

១៤ប្រសិនបើខ្ញុំបានខ្ពស់មុខបន្តិច ដោយនិយាយសរសើរពីបងប្អូនប្រាប់គាត់ ក៏ខ្ញុំមិនខ្មាសគាត់ដែរ។ សេចក្ដីដែលយើងសរសើរពីបងប្អូនប្រាប់ទីតូ គាត់នឹងឃើញថា ជាការពិតមែនដូចយើងធ្លាប់តែនិយាយអ្វីៗ គ្រប់យ៉ាងប្រាប់បងប្អូន ស្របតាមសេចក្ដីពិតយ៉ាងនោះដែរ។ ១៥ពេលគាត់នឹកឃើញថាបងប្អូនទាំងអស់គ្នា តែងតែយកចិត្តទុកដាក់ស្ដាប់បង្គាប់ និងទទួលគាត់ដោយគោរពកោតខ្លាចញាប់ញ័រផងនោះ គាត់មានចិត្តស្រឡាញ់បងប្អូនរឹតតែខ្លាំងឡើងៗ។ ១៦ខ្ញុំត្រេកអរណាស់ ព្រោះខ្ញុំអាចទុកចិត្តបងប្អូនក្នុងគ្រប់កិច្ចការទាំងអស់។

## អំពីការរៃប្រាក់

១យើងសូមជម្រាបបងប្អូន ឲ្យដឹងថា ព្រះជា
៨ម្ចាស់ បានប្រោសប្រណីព្រះសហគមន៍នានា
នៅស្រុកម៉ាសេដូន ២គឺទោះបីបងប្អូនទាំងនោះ
កំពុងជួបប្រទះទុក្ខវេទនាជាច្រើនយ៉ាងណាក្ដី ក៏
គេមានអំណរខ្លាំងក្រៃលែង ហើយទោះបីគេក្រ

តោកយ៉ាកយ៉ាងណាក្ដី ក៏គេនៅតែមានចិត្ត
សទ្ធាជ្រះថ្លាដ៏លើសលប់ដែរ។ ៣បងប្អូនទាំង
នោះ បានចូលប្រាក់តាមសមត្ថភាពរបស់ខ្លួន
ហើយខ្ញុំសូមបញ្ជាក់ថា គេធ្វើលើសពីសមត្ថ
ភាព និងដោយស្ម័គ្រអស់ពីចិត្តទៀតផង។ ៤ពួក
គេបានទទូចសុំយើងមេត្តាអនុញ្ញាត ឲ្យគេចូល
រួមបម្រើការងារនេះ គឺធ្វើប្រាក់ទៅជួយជនដ៏
វិសុទ្ធ[ត]។ ៥គេធ្វើដូច្នេះលើសពីសេចក្ដីសង្ឃឹម
របស់យើងទៅទៀត គឺមុនដំបូង គេថ្វាយខ្លួន
ទៅព្រះអម្ចាស់ បន្ទាប់មក គេក៏ដាក់ខ្លួនបម្រើ
យើង ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់
ដែរ។ ៦ហេតុនេះហើយ បានជាយើងអង្វរបងទី
តូ ឲ្យមកបង្ហើយការប្រមូលទាននេះពីបងប្អូន
ដូចគាត់បានចាប់ផ្ដើមរួចមកហើយ។ ៧បងប្អូន
បានចម្រើនឡើង យ៉ាងបរិបូណ៌គ្រប់វិស័យទាំង
អស់ ខាងជំនឿ ខាងសំនួនវោហារ បងប្អូនមាន
ចំណេះចេះដឹងមានចិត្តខ្នះខ្នែងគ្រប់យ៉ាង ព្រម
ទាំងមានចិត្តស្រឡាញ់យើងផង។ ហេតុនេះ
អំពីរឿងចូលប្រាក់ សូមបងប្អូនបានចម្រើន
ឡើងយ៉ាងបរិបូណ៌ដូច្នោះដែរ។ ៨ ខ្ញុំនិយាយ
បែបនេះមិនមែនបញ្ជាបងប្អូនទេ គឺខ្ញុំគ្រាន់តែ
ចង់ស្ទង់មើលចិត្តស្រឡាញ់ដ៏ស្មោះ របស់បង
ប្អូនដោយនិយាយ អំពីការខ្នះខ្នែងរបស់អ្នក
ឯទៀតៗប៉ុណ្ណោះ ៩ដ្បិតបងប្អូនស្គាល់ព្រះ
ហឫទ័យប្រោសប្រណី របស់ព្រះអម្ចាស់យេស៊ូ
គ្រីស្ដស្រាប់ហើយ គឺព្រះអង្គដែលមានសម្បត្តិ
សួគ៌ជាច្រើន ទ្រង់បានបន្ទាបព្រះកាយ មកជា
អ្នកក្រ ព្រោះតែបងប្អូន ដើម្បីឲ្យបងប្អូនបានទៅ
ជាអ្នកមាន ដោយភាពក្រីក្ររបស់ព្រះអង្គ។
១០ត្រង់នេះ ខ្ញុំគ្រាន់តែជូនយោបល់បងប្អូន
ប៉ុណ្ណោះ។ គួរគប្បីបង្ហើយកិច្ចការដែលបងប្អូន
បានចាប់ផ្ដើមធ្វើតាំងពីឆ្នាំទៅ។ បងប្អូនមិនត្រឹម
តែបានចាប់ផ្ដើមធ្វើមុនគេប៉ុណ្ណោះទេ គឺថែម
ទាំងបានផ្ដើមគំនិតទៀតផង។ ១១ដូច្នេះសូមបង
ប្អូនបង្ហើយការនេះយ៉ាងណាត្រូវធ្វើឲ្យបាន
សម្រេចជាស្ថាពរតាមសមត្ថភាពដែលបងប្អូន
មានយ៉ាងនោះដែរ។

១២កាលណាយើងមានឆន្ទៈល្អ យើងនឹង
បានគាប់ព្រះហឫទ័យព្រះជាម្ចាស់ តាមអ្វីៗ
ដែលយើងមាន គឺមិនមែនតាមអ្វីៗដែលយើង
គ្មាននោះទេ។ ១៣ក៏ប៉ុន្តែ មិនត្រូវឲ្យបងប្អូនជួយ
អ្នកដទៃ រហូតដល់ខ្លួនឯងខ្វះខាតនោះឡើយ
គឺគ្រាន់តែធ្វើឲ្យមានស្មើៗគ្នាប៉ុណ្ណោះ។ ១៤ក្នុង
កាលៈទេសៈសព្វថ្ងៃ អ្វីៗដែលបងប្អូនមាន
លើសពីសេចក្ដីត្រូវការ បងប្អូនយកទៅផ្គត់ផ្គង់
អស់អ្នកដែលខ្វះខាតលុះដល់ថ្ងៃមួយ ពេលបង
ប្អូនខ្វះខាតគេនឹងយកអ្វីៗ ដែលគេមានលើសពី
សេចក្ដីត្រូវការរបស់គេ មកផ្គត់ផ្គង់បងប្អូនវិញ។
ធ្វើដូច្នេះទើបមានស្មើគ្នា ១៥ដូចមានសេចក្ដីចែង
ទុកមកថា៖ «អ្នកប្រមូលបានច្រើន ក៏មិនមាន
ច្រើនជ្រុល រីឯអ្នកដែលប្រមូលបានបន្តិចបន្តួច
ក៏មិនខ្វះខាតអ្វីដែរ»[ថ]។

## លោកទីតូ និង សហការីរបស់លោក

១៦សូមអរព្រះគុណព្រះជាម្ចាស់ ដែលបាន
ប្រោសប្រទាន ឲ្យបងទីតូមានចិត្តខ្នះខ្នែង ចង់
ជួយបងប្អូនដូចយើងដែរ ១៧ដ្បិតគាត់បានយល់
ព្រមធ្វើតាមសំណូមពររបស់យើង ហើយលើស
ពីនេះទៅទៀត គាត់ក៏មានចិត្តខ្នះខ្នែងសម្រេច

ចិត្តដោយខ្លួនឯង ធ្វើដំណើរមករកបងប្អូន។
[១៨]យើងចាត់បងប្អូនម្នាក់ឲ្យមកជាមួយគាត់ គឺ
បងប្អូនម្នាក់ដែលព្រះសហគមន៍ទាំងអស់កោត
សរសើរក្នុងការប្រកាសដំណឹងល្អ។ [១៩]មិនតែ
ប៉ុណ្ណោះសោត ព្រះសហគមន៍បានជ្រើសរើស
គាត់ឲ្យរួមដំណើរជាមួយយើងក្នុងកិច្ចបម្រើ រៃ
ប្រាក់នេះ ដើម្បីលើកតម្កើងសិរីរុងរឿងរបស់
ព្រះអម្ចាស់ និងដើម្បីសម្ដែងឆន្ទៈល្អរបស់យើង
ដែរ

[២០]យើងចង់ជៀសវាង មិនឲ្យគេរិះគន់យើង
អំពីរបៀបចាត់ចែងប្រាក់ដែលរៃបានយ៉ាងច្រើន
នេះឡើយ [២១]ដ្បិតយើងចង់ធ្វើការល្អ មិនត្រឹម
តែនៅចំពោះព្រះភ័ក្ត្រ ព្រះអម្ចាស់ប៉ុណ្ណោះទេ គឺ
ថែមទាំងនៅចំពោះមុខមនុស្សទាំងអស់ទៀតផ
ង។ [២២]យើងចាត់បងប្អូនយើងម្នាក់ទៀត ឲ្យមក
ជាមួយអ្នកទាំងពីរ។ យើងធ្លាប់ល្បងលមើល
ចិត្តគាត់ជាច្រើនលើកច្រើនសា ហើយឃើញថា
គាត់ពិតជាមានចិត្តខ្នះខ្នែងមែន។ លើកនេះ
គាត់បានបង្ហាញនូវទឹកចិត្តខ្នះខ្នែងជាងមុនទៅ
ទៀត ព្រោះគាត់ទុកចិត្តបងប្អូនខ្លាំងណាស់។

[២៣]ចំពោះបងទីតូស គាត់ជាសហការីរបស់ខ្ញុំ
ហើយគាត់ធ្វើការរួមជាមួយខ្ញុំ ដើម្បីបម្រើបងប្អូ
ន។ រីឯបងប្អូនពីរនាក់ទៀតជាតំណាងរបស់
ព្រះសហគមន៍ និងជាសិរីរុងរឿងរបស់ព្រះគ្រី
ស្ត។ [២៤]ដូច្នេះ សូមបងប្អូនសម្ដែងឲ្យព្រះសហ
គមន៍នានាឃើញថា បងប្អូនស្រឡាញ់គេពិត
មែន និងឃើញថា សេចក្ដីដែលយើងនិយាយ
សរសើរអំពីបងប្អូនប្រាប់គេនោះ ពិតជាត្រឹមត្រូវ
មែន។

## ជំនួយផ្ញើទៅជូនជនដ៏វិសុទ្ធ

[១]ចំពោះរឿងផ្ញើជំនួយ ទៅជូនជនដ៏វិសុទ្ធ[ទ]
៩នោះ មិនបាច់ឲ្យខ្ញុំសរសេរជម្រាបបងប្អូនទេ
[២] ខ្ញុំស្គាល់ឆន្ទៈល្អរបស់បងប្អូនស្រាប់ហើយ
ហើយខ្ញុំក៏បាននិយាយសរសើរអំពីបងប្អូន
ប្រាប់អ្នកស្រុកម៉ាសេដូនថា «បងប្អូននៅស្រុក
អាខៃបានរៀបចំខ្លួនជាស្រេច តាំងពីឆ្នាំទៅ
ម្ល៉េះ»។ ចិត្តខ្នះខ្នែងរបស់បងប្អូន បានជំរុញអ្នក
ឯទៀតជាច្រើន ឲ្យមានចិត្តស្ទុះស្ទាឡើង។ [៣] ខ្ញុំ
បានចាត់ពួកបងប្អូនខ្លះមក ដើម្បីឲ្យឃើញថា
ពាក្យដែលយើងនិយាយសរសើរបងប្អូនត្រង់
ចំណុចនេះ មិនមែនខុសទេ គឺបងប្អូនពិតជា
រៀបចំខ្លួនជាស្រេច ដូចខ្ញុំនិយាយមែន។
[៤]ប្រសិនបើបងប្អូននៅ ស្រុកម៉ាសេដូនមក
ជាមួយខ្ញុំ ហើយឃើញថា បងប្អូនមិនទាន់
រៀបចំខ្លួនទេនោះ មិនត្រឹមតែយើងប៉ុណ្ណោះទេ
ត្រូវអាម៉ាស់មុខ គឺបងប្អូនក៏នឹងត្រូវអាម៉ាស់មុខ
ដែរ មកពីយើងទុកចិត្តលើបងប្អូនខ្លាំងពេក។
[៥] ហេតុនេះហើយ បានជាខ្ញុំយល់ឃើញថា ត្រូវ
តែសុំឲ្យបងប្អូននៅទីនោះ ធ្វើដំណើរមករកបង
ប្អូនមុនខ្ញុំ ដើម្បីរៀបចំប្រាក់ជំនួយ ដែលបងប្អូន
សន្យានោះឲ្យបានរួចរាល់។ ការនេះសឲ្យ
ឃើញថា បងប្អូនបានចូលប្រាក់ដោយចិត្ត
ទូលាយ មិនមែនដោយចង្អៀតចង្អល់ទេ។

[៦]សូមចងចាំថា អ្នកណាព្រោះតិចអ្នកនោះក៏
ច្រូតបានផលតិចដែរ រីឯអ្នកដែលព្រោះច្រើនបរិ
បូណ៌ ក៏ច្រូតបានផលច្រើនបរិបូណ៌ដែរ។
[៧] ហេតុនេះ ម្នាក់ៗត្រូវតែចូលប្រាក់តាមតែខ្លួន
សម្រេចចិត្ត ដោយមិននឹកស្ដាយ ឬ ទើសទ័ល

ឡើយ ដ្បិតព្រះជាម្ចាស់សព្វព្រះហឫទ័យនឹង
អ្នកដែលធ្វើអំណោយដោយចិត្តរីករាយ។ ៨ព្រះ
អង្គអាចនឹងប្រទានពរដ៏ហូរហៀរគ្រប់យ៉ាងដល់
បងប្អូន ដើម្បីឲ្យបងប្អូនមានអ្វីៗទាំងអស់ដែល
បងប្អូនត្រូវការយ៉ាងចាំបាច់នោះ ជានិច្ចហើយ
ថែមទាំងនៅសល់បរិបូណ៌ សម្រាប់ចែកទាន
ផង ៩ដូចមានចែងទុកមកថា៖ *«ព្រះអង្គចែក
អំណោយ ព្រះអង្គប្រទានឲ្យអ្នកក្រ។ ព្រះ
ហឫទ័យសុចរិតរបស់ព្រះអង្គនៅស្ថិតស្ថេររហូត
តរៀងទៅ»*[ធ]។

១០ព្រះអង្គដែល *«ប្រទានគ្រាប់ពូជដល់អ្នក
សាបព្រោះ និងប្រទានចំណីអាហារឲ្យគេផង
នោះ»*[ន] ទ្រង់ក៏ផ្ដល់គ្រាប់ពូជឲ្យបងប្អូននិងឲ្យ
គ្រាប់ពូជនោះកើនចំនួនឡើងដែរ ហើយព្រះ
អង្គនឹងធ្វើឲ្យសេចក្ដីសុចរិតរបស់បងប្អូន បង្កើត
ផលបានច្រើនឡើងថែមទៀត។ ១១ព្រះអង្គនឹង
ធ្វើឲ្យបងប្អូន ទៅជាអ្នកមានគ្រប់វិស័យទាំង
អស់ ដើម្បីឲ្យបងប្អូនមានចិត្តសទ្ធាជ្រះថ្លាគ្រប់
ជំពូក និងឲ្យអ្នកឯទៀតៗអរព្រះគុណព្រះជា
ម្ចាស់ ដោយយើងជួយគេ ១២ ដ្បិតការបម្រើក្នុង
កិច្ចប្រមូលប្រាក់នេះ មិនត្រឹមតែជួយផ្គត់ផ្គង់
សេចក្ដីត្រូវការរបស់អ្នកជឿប៉ុណ្ណោះទេ គឺថែម
ទាំងជួយគេ ឲ្យអរព្រះគុណព្រះជាម្ចាស់កាន់តែ
ច្រើនឡើងទៀតផង។ ១៣ ពេលគេយល់តម្លៃនៃ
ការជួយបម្រើដែលបងប្អូនធ្វើនេះ គេនាំគ្នាលើក
តម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ ព្រោះបង
ប្អូនសម្តែងឲ្យគេឃើញថា បងប្អូនពិតជាប្រតិប
ត្តិតាមដំណឹងល្អរបស់ព្រះគ្រីស្ត ដែលបងប្អូន
ប្រកាស ហើយបងប្អូនមានចិត្តទូលាយ ដោយ
យកអ្វីដែលបងប្អូនមានមកដាក់រួបរួមគ្នា ចែក
ជាមួយពួកគេ និងជាមួយមនុស្សទាំងអស់។
១៤គេអង្វរព្រះជាម្ចាស់ឲ្យបងប្អូន ដោយចិត្ត
ស្រឡាញ់ ព្រោះព្រះអង្គបានប្រោសប្រណី បង
ប្អូនយ៉ាងបរិបូណ៌លើសលប់។ ១៥សូមអរព្រះ
គុណព្រះជាម្ចាស់ចំពោះព្រះអំណោយទានដ៏
ប្រសើរបំផុតរបស់ព្រះអង្គរកថ្លែងពុំបាន។

## គ្រីស្ដទូតប៉ូលឆ្លើយការពារខ្លួន

១ខ្ញុំប៉ូលផ្ទាល់ ដែលគេតែងតែនិយាយថា
១០ពេលនៅជាមួយបងប្អូន ខ្ញុំមានឫកពា
សុភាព តែពេលនៅឆ្ងាយ ហ៊ានតឹងរ៉ឹងដាក់បង
ប្អូន ខ្ញុំសូមដាស់តឿនបងប្អូន ដោយចិត្តស្លូត
បូត និងដោយចិត្តល្អសប្បុរសមកពីព្រះគ្រីស្ត ២
ខ្ញុំសូមអង្វរបងប្អូនថា កុំបង្ខំចិត្តខ្ញុំឲ្យបែរទៅជា
តឹងតែង នៅពេលខ្ញុំមកដល់នោះឡើយ ដ្បិតខ្ញុំ
បានតាំងចិត្តរួចស្រេចហើយថា ខ្ញុំមិនខ្លាចនឹង
ស្ដីបន្ទោសអស់អ្នក ដែលចោទថាយើងរស់នៅ
តាមរបៀបលោកីយ៍នោះទេ។

៣ទោះបីយើងដែលមាននិស្ស័យជាមនុស្ស
លោកីយ៍ក៏ដោយ ក៏យើងមិនតយុទ្ធតាមរបៀប
លោកីយ៍ដែរ ៤ដ្បិតគ្រឿងសស្ត្រាវុធដែលយើង
ប្រើ មិនមែនជាអាវុធខាងលោកីយ៍ទេ គឺជា
អាវុធដ៏មានឫទ្ធានុភាពមកពីព្រះជាម្ចាស់ ដែល
អាចរំលំកំពែងបន្ទាយនានា[ប]។ យើងរំលំការរិះ
គិត ៥និងគំនិតឆ្មើងកន្ទ្រើងទាំងប៉ុន្មាន ដែល
រារាំងមិនឲ្យស្គាល់ព្រះជាម្ចាស់។ យើងកៀរ
ប្រមូលចិត្តគំនិត ឲ្យមកស្ដាប់បង្គាប់ព្រះគ្រីស្ដវិ
ញ។

៦នៅពេលណាបងប្អូនស្ដាប់បង្គាប់ទាំងស្រុងហើយនោះ យើងក៏ប្រុងប្រៀបសខ្លួនដាក់ទោសអស់អ្នកដែលមិនស្ដាប់បង្គាប់ដែរ។

៧សុំបងប្អូនពិចារណាឲ្យបានច្បាស់លាស់! ប្រសិនបើនរណាម្នាក់ជឿជាក់ថា ខ្លួនជាកូនចៅរបស់ព្រះគ្រីស្ដ អ្នកនោះតោងគិតឲ្យច្បាស់ថា បើខ្លួនជាកូនចៅរបស់ព្រះគ្រីស្ដ យើងក៏ជាកូនចៅរបស់ព្រះអង្គ ដូចគាត់ដែរ។ ៨ព្រះអម្ចាស់ប្រទានអំណាចឲ្យយើង ដើម្បីកសាងបងប្អូន មិនមែនដើម្បីបំផ្លាញបងប្អូនទេ។ ទោះបីខ្ញុំបាននិយាយអួតខ្លួនជ្រុលបន្តិចអំពីអំណាចនោះ ក៏ខ្ញុំមិនអៀនខ្មាសដែរ។ ៩ខ្ញុំមិនចង់ឲ្យបងប្អូនស្មានថា ខ្ញុំមានបំណងបំភ័យបងប្អូន តាមសំបុត្រទាំងនោះឡើយ ១០ដ្បិតមានគេថា«ពាក្យក្នុងសំបុត្ររបស់លោកប៉ូលធ្ងន់ៗណាស់ ហើយក៏តឹងរ៉ឹងផង តែពេលគាត់នៅទីនេះ គាត់មិនហ៊ានធ្វើអ្វីនរណាទេ ហើយក៏គ្មានវោហារអ្វីដែរ»។

១១អ្នកដែលនិយាយ ដូច្នេះត្រូវគិតថា ពេលយើងមិននៅយើងនិយាយបែបណា ពេលយើងនៅជាមួយ យើងក៏នឹងប្រព្រឹត្តបែបនោះដែរ[ធ]។ ១២យើងមិនហ៊ានលើកខ្លួន ឲ្យស្មើនឹងអ្នកខ្លះដែលតែងតាំងខ្លួនឯង ឬក៏ប្រៀបផ្ទឹមខ្លួនយើងទៅនឹងគេនោះឡើយ។ អ្នកទាំងនោះបានលើកខ្លួនតាំងជារង្វាស់សម្រាប់វាស់ខ្លួនឯង ហើយប្រៀបផ្ទឹមខ្លួនឯងទៅនឹងខ្លួនឯង![ព] គេគ្មានប្រាជ្ញាទាល់តែសោះ! ១៣រីឯយើងវិញ យើងមិនអួតខ្លួនហួសកម្រិតទេ គឺយើងធ្វើតាមកម្រិតនៃព្រំដែន ដែលព្រះជាម្ចាស់បានកំណត់ទុកដោយប្រទានឲ្យយើងបានមកដល់ស្រុកបងប្អូននេះ។ ១៤បងប្អូនស្ថិតនៅក្នុងព្រំដែន ដែលព្រះជាម្ចាស់បានកំណត់ទុកឲ្យយើង ដូច្នេះនៅពេលយើងបានមកដល់ទីនេះមុនគេ ដើម្បីនាំដំណឹងល្អរបស់ព្រះគ្រីស្ដ យើងមិនធ្វើអ្វីហួសកំណត់ព្រំដែននេះទេ។ ១៥យើងមិនអួតខ្លួនហួសកម្រិត គឺមិនអួតអំពីកិច្ចការ ដែលអ្នកដទៃបានធ្វើនោះឡើយ។ យើងសង្ឃឹមថា ជំនឿរបស់បងប្អូននឹងចម្រើនឡើង ហើយយើងអាចនឹងបំពេញកិច្ចការកាន់តែប្រសើរឡើងថែមទៀត ក្នុងចំណោមបងប្អូន តាមព្រំដែនដែលព្រះជាម្ចាស់បានកំណត់ទុកឲ្យយើង។ ១៦ បន្ទាប់មកយើងនឹងប្រកាសដំណឹងល្អនៅតាមតំបន់នានានៅខាងនាយស្រុកបងប្អូន ដោយមិនអួតខ្លួនអំពីកិច្ចការដែលអ្នកដទៃបានធ្វើរួចស្រេចមកហើយក្នុងតំបន់របស់គេឡើយ។ ១៧អ្នកណាចង់អួតអាងត្រូវអួតអាងអំពីកិច្ចការ ដែលព្រះអម្ចាស់បានប្រព្រឹត្ត[ភ]។ ១៨អ្នកដែលគួរឲ្យគេទុកចិត្ត មិនមែនអ្នកដែលតែងតាំងខ្លួនឯងទេ គឺអ្នកដែលព្រះអម្ចាស់តែងតាំងនោះវិញ។

## គ្រីស្ដទូតប៉ូល និង គ្រីស្ដទូតក្លែងក្លាយ

១សូមបងប្អូនអត់ឱន ឲ្យខ្ញុំផង ពេលនេះ ខ្ញុំ
១១និយាយដូចជាមនុស្សលេលា សូមអត់ឱនឲ្យខ្ញុំផង! ២ព្រោះខ្ញុំប្រច័ណ្ឌ[ម]មកបងប្អូន ដោយចិត្តប្រច័ណ្ឌមកពីព្រះជាម្ចាស់ ដ្បិតខ្ញុំបានដណ្ដឹងបងប្អូន ឲ្យធ្វើជាគូដណ្ដឹងនឹងស្វាមីតែមួយគត់ គឺខ្ញុំនាំបងប្អូនមក ដូចជានាំក្រមុំព្រហ្មចារី យកទៅថ្វាយព្រះគ្រីស្ដ។ ៣ប៉ុន្តែ ខ្ញុំបារម្ភថា ពស់បានល្បួងនាងអេវ៉ា ដោយកលល្បិចរបស់វាយ៉ាងណា ចិត្តគំនិតរបស់បងប្អូន បែរទៅជា

សៅហ្មង លះបង់ចិត្តស្មោះសរ និងចិត្តបរិសុទ្ធ
ចំពោះព្រះគ្រីស្ទយ៉ាងនោះដែរ ៤ព្រោះថា ពេល
មាននរណាម្នាក់មកប្រកាសអំពីព្រះយេស៊ូណា
មួយផ្សេងទៀត ក្រៅពីព្រះយេស៊ូដែលយើង
ប្រកាសនោះ ឬមួយបើបងប្អូនទទួលវិញ្ញាណ
ណាផ្សេង ក្រៅពីព្រះវិញ្ញាណដែលបងប្អូនបាន
ទទួលហើយនោះ ឬក៏ទទួលដំណឹងល្អណាមួយ
ទៀត ក្រៅពីដំណឹងល្អដែលបងប្អូនបានទទួល
នោះ បងប្អូនចេះតែអត់ឱនឲ្យគេយ៉ាងស្រួ
លៗ។

៥ខ្ញុំយល់ឃើញថា ខ្ញុំមិនមែនអន់ជាងអស់
អ្នកដែលតាំងខ្លួន ជាមហាគ្រីស្ទទូតទាំងនោះ
ត្រង់កន្លែងណាមួយឡើយ ៦ថ្វីដ្បិតតែខ្ញុំមិនសូវ
មានវោហារក៏ដោយ ផ្នែកខាងចំណេះវិញ ខ្ញុំក៏
មិនអន់ដែរ ដូចយើងធ្លាប់បានបង្ហាញឲ្យបងប្អូន
ឃើញក្នុងគ្រប់វិស័យ និងគ្រប់ពេលវេលាស្រាប់
ហើយ។

៧ពេលខ្ញុំប្រកាសដំណឹងល្អ របស់ព្រះជា
ម្ចាស់ ប្រាប់បងប្អូនដោយឥតគិតថ្លៃនោះ ខ្ញុំបាន
បន្ទាបខ្លួន ដើម្បីឲ្យបងប្អូនបានថ្កើងឡើង។ តើ
ខ្ញុំធ្វើដូច្នេះ បានសេចក្ដីថា ខ្ញុំធ្វើខុសឬ?។ ៨ខ្ញុំ
បានទទួលប្រាក់ពីព្រះសហគមន៍ឯទៀតៗ ធ្វើ
ឲ្យគេខ្វះខាតខ្លះៗ ដើម្បីបម្រើបងប្អូន។ ៩ពេល
ខ្ញុំនៅជាមួយបងប្អូនបើខ្ញុំខ្វះខាតអ្វីៗ ខ្ញុំពុំបានធ្វើ
ជាបន្ទុកដល់នរណាម្នាក់ឡើយ ដ្បិតបងប្អូនមក
ពីស្រុកម៉ាសេដូន បានជួយផ្គត់ផ្គង់នូវអ្វីៗដែល
ខ្ញុំត្រូវការ។ ក្នុងគ្រប់កិច្ចការ ខ្ញុំបានជៀសវាង កុំ
ឲ្យខ្លួនខ្ញុំទៅជាបន្ទុកដល់បងប្អូន ហើយខ្ញុំនឹង
ជៀសវាងតទៅមុខទៀត។ ១០ខ្ញុំសូមបញ្ជាក់
ដោយមានសេចក្ដីពិតរបស់ព្រះគ្រីស្ទនៅក្នុងថា
ក្នុងស្រុកអាខៃទាំងមូល គ្មាននរណាអាចបង្អាប់
កិត្តិយសខ្ញុំ ត្រង់ចំណុចនេះបានឡើយ។ ១១
ហេតុអ្វីបានជាខ្ញុំធ្វើដូច្នេះ? តើមកពីខ្ញុំមិន
ស្រឡាញ់បងប្អូនឬ? ទេ! ព្រះជាម្ចាស់ជ្រាប
ស្រាប់ហើយថា ខ្ញុំស្រឡាញ់បងប្អូន។

១២ការដែលខ្ញុំធ្វើនេះ ខ្ញុំនឹងធ្វើតទៅមុខ
ទៀត ដើម្បីកុំឲ្យអស់អ្នកដែលចង់រកលេសនឹង
អួតខ្លួនដោយពោលថា គេធ្វើការដូចយើងដែរ
នោះ អាចរកលេសបានសោះឡើយ។ ១៣ជន
ប្រភេទនោះ សុទ្ធតែជាគ្រីស្ទទូតក្លែងក្លាយ អ្នក
បន្លំធ្វើការ អ្នកក្លែងខ្លួនធ្វើជាទូតរបស់ព្រះគ្រី
ស្ទ។ ១៤ត្រង់នេះសូមកុំឆ្ងល់អ្វីឡើយ សូម្បីតែ
មារសាតាំងផ្ទាល់ក៏បានក្លែងខ្លួនធ្វើជាទេវតានៃ
ពន្លឺដែរ។

១៥ដូច្នេះ បើពួកអ្នកបម្រើរបស់វាក្លែងខ្លួនធ្វើ
ជាអ្នកបម្រើសេចក្ដីសុចរិតនោះ គ្មានអ្វីចម្លែក
សោះឡើយ។ អ្នកទាំងនោះនឹងត្រូវវិនាសស្រប
តាមអំពើដែលខ្លួនបានប្រព្រឹត្តជាមិនខាន។

## ទុក្ខលំបាករបស់គ្រីស្ទទូតប៉ូល

១៦ខ្ញុំសូមបញ្ជាក់ម្ដងទៀតថា កុំឲ្យនរណា
ម្នាក់យល់ថា ខ្ញុំជាមនុស្សលេលាឡើយ ឬមួយ
ទុកឲ្យខ្ញុំលេលាទៅចុះ ដើម្បីឲ្យខ្ញុំអាចអួតខ្លួន
បន្តិចដែរ។ ១៧សេចក្ដីដែលខ្ញុំនិយាយនេះ ខ្ញុំមិន
និយាយស្របតាមព្រះអម្ចាស់ទេ គឺខ្ញុំនិយាយ
ដូចជាមនុស្សលេលាវិញ ដោយយល់ឃើញថា
ខ្ញុំមានមូលហេតុនឹងអួតខ្លួន ប្រាកដមែន។
១៨ដោយមានមនុស្សជាច្រើន លើកខ្លួនតាម

របៀបលោកីយ៍ នោះខ្ញុំក៏អាចនឹងលើកខ្លួនឯងតាមរបៀបលោកីយ៍ដែរ! [១៩]បងប្អូនជាមនុស្សដឹងខុសត្រូវ តែបងប្អូនចេះទ្រាំទ្រនឹងមនុស្សលោកបាន [២០]គឺទ្រាំទ្រឲ្យគេជិះជាន់ កេងប្រវ័ញ្ចរឹបអូសយកទ្រព្យសម្បត្តិ ប្រមាថមាក់ងាយ និងឲ្យគេទះកំផ្លៀងផង។ [២១]ខ្ញុំសូមជម្រាបថាគួរឲ្យខ្មាសណាស់! យើងហាក់បីដូចជាទន់ខ្សោយពេក។

ក៏ប៉ុន្តែ បើគេហ៊ានអះអាងត្រង់ចំណុចណាមួយ (ខ្ញុំនិយាយដូចជាមនុស្សលេលាមែន)ខ្ញុំក៏ហ៊ានត្រង់ចំណុចនោះ ដូចគេដែរ។

[២២]អ្នកទាំងនោះ ជាសាសន៍ហេប្រឺឬ? ខ្ញុំក៏ជាសាសន៍ហេប្រឺដែរ! អ្នកទាំងនោះ ជាសាសន៍អ៊ីស្រាអែលឬ? ខ្ញុំក៏ជាសាសន៍អ៊ីស្រាអែលដែរ! អ្នកទាំងនោះជាពូជពង្សរបស់លោកអប្រាហាំឬ? ខ្ញុំក៏ជាពូជពង្សរបស់លោកដែរ! [២៣] អ្នកទាំងនោះ ជាអ្នកបម្រើរបស់ព្រះគ្រីស្ដឬ? ខ្ញុំសូមនិយាយ ដូចជាមនុស្សវង្វេងស្មារតីទាំងស្រុងទៅចុះ ថា ខ្ញុំជាអ្នកបម្រើរបស់ព្រះអង្គ លើសអ្នកទាំងនោះទៅទៀត។ ខ្ញុំធ្វើការនឿយហត់ច្រើនជាងអ្នកទាំងនោះ ខ្ញុំបានជាប់ឃុំឃាំងច្រើនជាង ខ្ញុំត្រូវគេវាយដំច្រើនជាងហួសប្រមាណ ហើយខ្ញុំក៏មានគ្រោះថ្នាក់ជិតស្លាប់ ជាញឹកញាប់ដែរ។ [២៤]ខ្ញុំត្រូវជនជាតិយូដាវាយសាមសិបប្រាំបួនរំពាត់[ឃ]ចំនួនប្រាំដង។ [២៥]គេវាយខ្ញុំនឹងដំបងចំនួនបីលើក គេយកដុំថ្មគប់សម្លាប់ខ្ញុំម្ដង ខ្ញុំត្រូវលិចសំពៅបីដង ហើយមានម្ដង ខ្ញុំអណ្ដែតនៅក្នុងសមុទ្រមួយថ្ងៃមួយយប់។ [២៦]ពេលខ្ញុំធ្វើដំណើរ ខ្ញុំតែងតែជួបប្រទះគ្រោះថ្នាក់ជាញឹកញាប់នៅតាមទន្លេ គ្រោះថ្នាក់ដោយចោរប្លន់ គ្រោះថ្នាក់មកពីជនរួមជាតិរបស់ខ្ញុំ គ្រោះថ្នាក់មកពីសាសន៍ដទៃ គ្រោះថ្នាក់ក្នុងទីក្រុង គ្រោះថ្នាក់នៅវាលរហោស្ថាន គ្រោះថ្នាក់នៅក្នុងសមុទ្រ គ្រោះថ្នាក់ព្រោះតែពួកបងប្អូនក្លែងក្លាយ។ [២៧]ខ្ញុំបានធ្វើការទាំងនឿយ លំបាក និងត្រូវអត់ងងុយ អត់បាយ អត់ទឹកជាញឹកញាប់។ ខ្ញុំត្រូវតមអាហារ ត្រូវរងា និងខ្វះខាតសម្លៀកបំពាក់ជាញឹកញាប់។ [២៨]លើសពីនេះទៅទៀត ខ្ញុំខ្វល់ខ្វាយរៀងរាល់ថ្ងៃដោយគិតដល់ព្រះសហគមន៍ទាំងអស់ផងដែរ! [២៩]ប្រសិនបើមាននរណាម្នាក់ទន់ខ្សោយ ខ្ញុំក៏ទន់ខ្សោយដែរ ប្រសិនបើមាននរណាម្នាក់ឃ្លាតចេញពីជំនឿ ខ្ញុំក៏ឈឺចុកចាប់ណាស់! [៣០]ប្រសិនបើខ្ញុំត្រូវអួតខ្លួននោះ ខ្ញុំនឹងអួតតែអំពីភាពទន់ខ្សោយរបស់ខ្ញុំប៉ុណ្ណោះ។ [៣១]ព្រះជាម្ចាស់ដែលជាព្រះបិតារបស់ព្រះអម្ចាស់យេស៊ូទ្រង់ជ្រាបស្រាប់ហើយថា ខ្ញុំមិននិយាយកុហកទេ (សូមលើកតម្កើងព្រះអង្គអស់កល្បជានិច្ច!)។ [៣២]កាលខ្ញុំនៅក្រុងដាម៉ាស អភិបាលក្រុងរបស់ស្ដេចអរេតា បានដាក់ទាហានឲ្យយាមទ្វារ ក្រុងដើម្បីចាំចាប់ខ្ញុំ [៣៣]ប៉ុន្តែ គេដាក់ខ្ញុំក្នុងជាលមួយសម្រូតចុះតាមបង្អួចកំពែង ហើយខ្ញុំបានគេចផុតពីកណ្ដាប់ដៃលោក[រ]។

## គ្រីស្ដទូតប៉ូលនិមិត្តឃើញការអស្ចារ្យ

[១]តើខ្ញុំត្រូវតែអួតខ្លួនឬ? ទោះបីអួតខ្លួន គ្មាន
១២ប្រយោជន៍អ្វីក៏ដោយ ក៏ខ្ញុំសូមនិយាយអំពីការអស្ចារ្យដែលព្រះអម្ចាស់បានប្រោសឲ្យខ្ញុំនិមិត្តឃើញ និងសម្ដែងឲ្យខ្ញុំដឹង។ [២]ខ្ញុំស្គាល់

បុរសម្នាក់ ដោយជឿព្រះគ្រីស្ដ កាលពីដប់បួនឆ្នាំមុន ព្រះអម្ចាស់បានលើកគាត់ឡើងទៅដល់ស្ថានសួគ៌ ជាន់ទីបី[ល] (ប៉ុន្តែ ខ្ញុំមិនដឹងថា រូបកាយគាត់ឡើងទៅ ឬមួយគាត់គ្រាន់តែនិមិត្តឃើញ[វ] មានតែព្រះជាម្ចាស់ប៉ុណ្ណោះទ្រង់ជ្រាប)។ [៣]ខ្ញុំក៏ដឹងថា ព្រះអម្ចាស់លើកបុរសនោះ ទៅដល់ស្ថានបរមសុខ (ប៉ុន្តែ ខ្ញុំមិនដឹងថា រូបកាយរបស់គាត់ឡើងទៅ ឬ មួយគាត់គ្រាន់តែនិមិត្តឃើញ មានតែព្រះជាម្ចាស់ប៉ុណ្ណោះទ្រង់ជ្រាប)។

[៤]គាត់បានឮព្រះបន្ទូលដ៏អស្ចារ្យ រកថ្លែងពុំបានដែលគ្មានមនុស្សណាមានសិទ្ធិនឹងនិយាយឡើងវិញបានទេ។ [៥]ខ្ញុំអួតតែពីបុរសនោះ រីឯខ្ញុំវិញ ខ្ញុំមិនអួតខ្លួនខ្ញុំផ្ទាល់ឡើយ ខ្ញុំអួតតែពីភាពទន់ខ្សោយរបស់ខ្ញុំប៉ុណ្ណោះ។ [៦]ប្រសិនបើខ្ញុំចង់អួតខ្លួន ខ្ញុំក៏មិនមែនល្ងីល្ងើដែរ ព្រោះខ្ញុំគ្រាន់តែនិយាយសេចក្ដីពិត។ ប៉ុន្តែ ខ្ញុំសុខចិត្តនៅស្ងៀមវិញក្រែងលោមាននរណាម្នាក់ស្មានថា ខ្ញុំមានឋានៈខ្ពស់លើសពីភាពដែលគេឃើញ និងលើសពីពាក្យដែលខ្ញុំនិយាយ។ [៧]ព្រះជាម្ចាស់បានដាក់បន្លាមួយក្នុងរូបកាយខ្ញុំ[ស] ដើម្បីកុំឲ្យខ្ញុំអួតខ្លួន ព្រោះតែការអស្ចារ្យដ៏ប្រសើរបំផុតដែលព្រះអង្គបានសម្ដែងឲ្យខ្ញុំឃើញ គឺដូចជាមានតំណាងរបស់មារសាតាំងមកធ្វើទារុណកម្មខ្ញុំ កុំឲ្យខ្ញុំអួតខ្លួនបានឡើយ។

[៨]ខ្ញុំអង្វរព្រះអម្ចាស់ចំនួនបីដង សូមទ្រង់មេត្តាដកយកបន្លានេះ ចេញពីរូបកាយខ្ញុំ។

[៩]ក៏ប៉ុន្តែ ព្រះអង្គមានព្រះបន្ទូលមកខ្ញុំថា៖ «ការប្រោសប្រណីរបស់យើង ល្មមគ្រប់គ្រាន់សម្រាប់អ្នកហើយ ដ្បិតឫទ្ធានុភាពរបស់យើងលេចចេញមកយ៉ាងខ្លាំងបំផុត ក្នុងមនុស្សទន់ខ្សោយ»។ ដូច្នេះ ខ្ញុំចូលចិត្តអួតខ្លួនអំពីភាពទន់ខ្សោយរបស់ខ្ញុំជាង ដើម្បីឲ្យឫទ្ធានុភាពរបស់ព្រះគ្រីស្ដ មកសណ្ឋិតលើខ្ញុំ។

[១០]ហេតុនេះ ព្រោះតែព្រះគ្រីស្ដ ខ្ញុំអរសប្បាយនៅពេលខ្ញុំទន់ខ្សោយ នៅពេលគេជេរប្រមាថ នៅពេលខ្វះខាត នៅពេលគេបៀតបៀន នៅពេលតប់ប្រមល់ ដ្បិតពេលណាខ្ញុំទន់ខ្សោយ គឺពេលនោះហើយ ដែលខ្ញុំមានកម្លាំង។

## គ្រីស្តទូតប៉ូលមានចិត្តស្មោះត្រង់

[១១]ខ្ញុំនិយាយដូច្នេះ ដូចជាមនុស្សលេលាហើយ គឺមកពីបងប្អូនបង្ខំខ្ញុំ ដ្បិតបងប្អូនហ្នឹងហើយ ដែលត្រូវគាំទ្រខ្ញុំ ទោះបីខ្ញុំជាមនុស្សឥតបានការក្ដី ក៏ខ្ញុំមិនអន់ជាងមហាគ្រីស្ដទូតទាំងនោះដែរ។ [១២]មានសញ្ញាសម្គាល់ផ្សេងៗបានកើតឡើងក្នុងចំណោមបងប្អូន ដែលបញ្ជាក់ថាខ្ញុំជាគ្រីស្ដទូត គឺមានការអត់ធ្មត់គ្រប់យ៉ាង មានទីសម្គាល់ឫទ្ធិបាដិហារិយ៍ និងការអស្ចារ្យផ្សេងៗ។ [១៣]បងប្អូនមិនបានទទួលអ្វីតិចជាងព្រះសហគមន៍ឯទៀតៗនោះឡើយ វៀរលែងតែខ្ញុំមិនដែលបានធ្វើជាបន្ទុកដល់បងប្អូនប៉ុណ្ណោះ សូមបងប្អូនអភ័យទោសឲ្យខ្ញុំ ចំពោះអយុត្តិធម៌នេះផង។

[១៤]ឥឡូវនេះ ខ្ញុំរៀបចំខ្លួនជាស្រេច ដើម្បីមករកបងប្អូនជាលើកទីបី ប៉ុន្តែ ខ្ញុំមិនធ្វើជាបន្ទុកដល់បងប្អូនទេ ព្រោះខ្ញុំមកមិនមែនប្រាថ្នាចង់

បានសម្បត្តិរបស់បងប្អូនឡើយ គឺចង់បានបង
ប្អូនផ្ទាល់តែម្តង។ ធម្មតាកូនចៅមិនដែល
ប្រមូលសម្បត្តិជូនឪពុកម្តាយទេ គឺឪពុកម្តាយ
វិញទេតើ ដែលប្រមូលសម្បត្តិទុកឲ្យកូន!
១៥ ចំពោះខ្ញុំ ខ្ញុំពេញចិត្តនឹងចំណាយអ្វីៗដែលខ្ញុំ
មាន ហើយខ្ញុំក៏ចំណាយខ្លួនខ្ញុំថែមទៀត ដើម្បី
ជាប្រយោជន៍ដល់ជីវិត[ហ]បងប្អូនដែរ។ បើខ្ញុំ
ស្រឡាញ់បងប្អូនខ្លាំងយ៉ាងហ្នឹងទៅហើយ តើ
បងប្អូនស្រឡាញ់ខ្ញុំតិចជាងឬ?

១៦យើងសន្មតទៅចុះថា ខ្ញុំពុំបានធ្វើជាបន្ទុក
ដល់បងប្អូនមែន តែប្រហែលជាមានអ្នកខ្លះថា
ខ្ញុំជាមនុស្សមានពុតត្បុត ប្រើកលល្បិចបោក
ប្រាសបងប្អូន។ ១៧តើខ្ញុំមានដែលបោកប្រាស
បងប្អូនតាមរយៈអ្នកដែលខ្ញុំចាត់មករកបងប្អូន
នោះទេ? ១៨ខ្ញុំបានអង្វរបងទីតុស ឲ្យមករកបង
ប្អូន ហើយខ្ញុំក៏ចាត់បងប្អូនម្នាក់ទៀត ឲ្យមក
ជាមួយគាត់ដែរ តើបងទីតុស បានបោកប្រាសបង
ប្អូនឬ? តើយើងទាំងពីរនាក់ មិនបានប្រកាន់
យកចិត្តគំនិត និងដើរ តាមគន្លងតែមួយទេឬ?

១៩តាំងពីយូរមកហើយ ប្រហែលជាបងប្អូន
ចេះតែស្មានថា យើងនិយាយដោះ សានៅ
ចំពោះមុខបងប្អូន! ទេ! យើងនិយាយដោយរួម
ជាមួយព្រះគ្រីស្ត នៅចំពោះ ព្រះភក្ត្រព្រះជាម្ចា
ស់។ បងប្អូនជាទីស្រឡាញ់អើយ! យើង
និយាយសេចក្តីទាំងនេះ ដើម្បីកសាងជំនឿបង
ប្អូនតែប៉ុណ្ណោះ ២០ដ្បិតខ្ញុំបារម្ភខ្លាចក្រែងលោ
ពេលខ្ញុំមកដល់ ខ្ញុំមិនឃើញបងប្អូនមាន
លក្ខណៈ ដូចដែលខ្ញុំចង់ឃើញ ហើយក៏ខ្លាច
ក្រែងបងប្អូនឃើញខ្ញុំខុសលក្ខណៈ ដែលបង
ប្អូនចង់ឃើញនោះដែរ។ ខ្ញុំបារម្ភ ក្រែងលោមាន
ការទាស់ទែងគ្នា ច្រណែនគ្នាខឹងសម្បារ
ប្រណាំងប្រជែងនិយាយដើមគ្នា បរិហារកេរ្តិ៍គ្នា
អួតបំប៉ោង ខ្វះសណ្តាប់ធ្នាប់។ ២១ខ្ញុំបារម្ភក្រែង
លោពេលខ្ញុំមកដល់លើកក្រោយ ព្រះរបស់ខ្ញុំ
នឹងបំបាក់មុខខ្ញុំនៅចំពោះមុខបងប្អូន ហើយខ្ញុំ
ត្រូវយំសោក ព្រោះតែបងប្អូនជាច្រើននាក់ដែល
បានប្រព្រឹត្តអំពើបាបកាលពីមុន តែមិនទាន់
បានប្រែចិត្តគំនិត លះបង់អំពើសៅហ្មង ប្រាស
ចាកសីលធម៌ និងកាមគុណថោកទាបដែលខ្លួន
បានប្រព្រឹត្តនៅឡើយ។

## ពាក្យផ្ញើសួរសុខទុក្ខ

១នេះជា លើកទីបីហើយដែលខ្ញុំមករកបង
១៣ប្អូន។ ត្រូវសម្រួលរឿងទាំងអស់ ដោយ
មានសាក្សីពីរ ឬបីនាក់[ឡ]។ ២កាលខ្ញុំនៅជាមួយ
បងប្អូនជាលើកទីពីរ ខ្ញុំបាននិយាយសេចក្តីនេះ
រួចស្រេចហើយ ហើយឥឡូវនេះ ពេលដែលខ្ញុំ
ឆ្ងាយ ខ្ញុំសូមជម្រាបអស់អ្នកដែលបានប្រព្រឹត្ត
អំពើបាបកាលពីមុន និងសូមជម្រាបអ្នកឯទៀត
ៗទាំងអស់ ឲ្យបានដឹងជាមុនថា បើខ្ញុំវិលមករក
បងប្អូនវិញនោះ ខ្ញុំនឹងមិនប្រណីនរណាម្នាក់
ឡើយ ៣ដ្បិតបងប្អូនចង់បានភស្តុតាងថា ព្រះ
គ្រីស្តមានព្រះបន្ទូលដោយសារខ្ញុំ។ ព្រះអង្គមិន
ទន់ខ្សោយចំពោះបងប្អូនទេ គឺព្រះអង្គបង្ហាញ
ឫទ្ធានុភាពនៅកណ្តាលចំណោមបងប្អូនវិញ។
៤ព្រះអង្គត្រូវគេឆ្កាង ដោយព្រះអង្គមានភាពទន់
ខ្សោយ ប៉ុន្តែ ព្រះអង្គមានព្រះជន្មថ្មីដ៏រុងរឿង
ដោយឫទ្ធានុភាពរបស់ព្រះជាម្ចាស់។ រីឯយើង
វិញ ក៏ដូច្នោះដែរ យើងទន់ខ្សោយរួមជាមួយ

ព្រះអង្គមែន ប៉ុន្តែ ដោយយល់ដល់បងប្អូន
យើងមានជីវិតរស់រួមជាមួយព្រះអង្គ ដោយ
ឫទ្ធានុភាពរបស់ព្រះជាម្ចាស់។
៥សូមបងប្អូនល្បងមើលខ្លួនឯងទៅ តើបង
ប្អូននៅតែមានជំនឿមែនឬយ៉ាងណា សូមបង
ប្អូនពិនិត្យពិច័យខ្លួនឯងមើលទៅចុះ! បងប្អូន
មិនទទួលស្គាល់ទេឬថា ព្រះយេស៊ូគ្រីស្តគង់នៅ
ក្នុងបងប្អូន! ឬមួយមានតែបងប្អូនឃើញថា ព្រះ
អង្គមិនគង់នៅជាមួយ![អ] ៦ខ្ញុំសង្ឃឹមថា បងប្អូន
ពិតជាដឹងថា ព្រះអង្គគង់នៅជាមួយយើងមែន
[ក]។ ៧យើងអង្វរព្រះជាម្ចាស់ សូមកុំឲ្យបងប្អូន
ប្រព្រឹត្តអំពើអាក្រក់អ្វីឡើយ។ យើងគ្មានបំណង
ចង់បង្ហាញភស្តុតាងថា យើងមានព្រះអង្គគង់
ជាមួយ ហើយនោះទេ យើងគ្រាន់តែចង់ឃើញ
បងប្អូនប្រព្រឹត្តអំពើល្អប៉ុណ្ណោះ ទោះបីការពិ
និត្យពិច័យនេះ បែរជាបង្ហាញថា យើងគ្មានភស្តុ
តាង អំពីព្រះអង្គគង់ជាមួយក៏ដោយ ៨ ដ្បិត
យើងមិនអាចប្រឆាំងនឹងសេចក្តីពិតបានឡើយ
គឺយើងគ្រាន់តែអាចបម្រើសេចក្តីពិតប៉ុណ្ណោះ។
៩យើងសប្បាយចិត្តនៅពេលណាយើងទន់
ខ្សោយ ហើយបងប្អូនមានកម្លាំង។ យើង
អធិដ្ឋានសុំសេចក្តីតែមួយនេះ គឺសូមឲ្យបងប្អូន
បានគ្រប់លក្ខណៈ។

១០ហេតុនេះហើយ បានជាពេលខ្ញុំនៅឆ្ងាយ
ខ្ញុំសរសេរសេចក្តីនេះមកជូនបងប្អូន។ ដូច្នេះ
កាលណាខ្ញុំមកដល់ ខ្ញុំមិនបាច់និយាយតឹងរ៉ឹង
មកកាន់បងប្អូនតាមអំណាច ដែលព្រះអម្ចាស់
បានប្រទានមកដល់ខ្ញុំនោះឡើយ។ ព្រះអង្គ
ប្រទានអំណាចនេះមកខ្ញុំ មិនមែនដើម្បីបំផ្លាញ
ទេ គឺដើម្បីកសាងវិញ។

១១នៅទីបញ្ចប់ ចូរបងប្អូនមានអំណរឡើង
ចូរខំប្រឹងឲ្យបានគ្រប់លក្ខណៈ ចូរលើកទឹកចិត្ត
គ្នា ចូរមានចិត្តគំនិតតែមួយ ចូររស់នៅដោយ
សុខសាន្តជាមួយគ្នា នោះព្រះជាម្ចាស់ ដែល
ប្រភពនៃសេចក្តីស្រឡាញ់ និងសេចក្តីសុខ
សាន្ត មុខជាគង់ជាមួយបងប្អូនមិនខាន។

១២ចូរជម្រាបសួរគ្នាទៅវិញទៅមក ដោយ
ស្និទ្ធស្នាលផង[ខ]។ ជនដ៏វិសុទ្ធទាំងអស់ក៏សូម
ជម្រាបសួរមកបងប្អូនដែរ។

១៣សូមព្រះយេស៊ូគ្រីស្តជាអម្ចាស់ ប្រោស
ប្រណីដល់បងប្អូន សូមព្រះជាម្ចាស់សម្តែងព្រះ
ហឫទ័យស្រឡាញ់ និងសូមព្រះវិញ្ញាណដ៏វិសុទ្ធ
ប្រោសឲ្យបងប្អូនរួបរួមជាមួយគ្នាផង។

ក. ឯកសារដើមខ្លះមានសរសេរថា: «ដោយចិត្តដ៏វិសុទ្ធ»។

ខ. «បាតដៃជាខ្នងដៃ»: ពាក្យដើម «បានដើម « បាទៗនិងទេៗ»។

គ. «ចាក់ប្រេង»: មានន័យថាព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធឲ្យមកសណ្ឋិតលើអ្នកជឿ។

ឃ. ពាក្យដើមបើកទ្វារ។

ង. មានអ្នកខ្លះចោទប្រកាន់លោកប៉ូលថាជាគ្រីស្តទូតក្លែងក្លាយ មកពីគ្មានសំបុត្រតែងតាំង។ ប៉ុន្តែលោកប៉ូលបានទទួលមុខងារ ជាគ្រីស្តទូតពីព្រះយេស៊ូផ្ទាល់ នៅពេលលោកបានឃើញព្រះអង្គនៅតាមផ្លូវទៅក្រុងដាម៉ាស។

ច. សូមអានសេរីភាព(និក្ខមនំ) ៣៤.៣៤។

ឆ. យើងអាចបកប្រែម៉្យាងទៀតថា « ស្នាព្រះហស្តរបស់ព្រះជាម្ចាស់ដែលជាព្រះវិញ្ញាណ»។

ជ. ពាក្យដើម «រូបភាពឬ គំនូរ»។ ព្រះគ្រីស្ដជាតំណាងរបស់ព្រះជាម្ចាស់ មានន័យថា ព្រះអង្គធ្វើឲ្យមនុស្សលោកឃើញព្រះជាម្ចាស់ ឬមនុស្សលោកឃើញព្រះជាម្ចាស់តាមរយៈព្រះយេស៊ូ។

ឈ. «មុខងារដ៏ប្រសើរនេះ» ពាក្យដើម« កំណប់»មានន័យថា មុខងារប្រកាសផ្សាយដំណឹងល្អ ដូចមាននិយាយនៅ ៤.១។

ញ. ពោលគឺការឈឺចាប់របស់ព្រះយេស៊ូនៅលើឈើឆ្កាងនៅពេលព្រះអង្គសោយទិវង្គត។

ដ. ទំនុកតម្កើង ១១៦.១០។

ឋ. ពាក្យដើម «មនុស្សខាងក្នុង» ដែលសំដៅទៅលើការគិតគូរពិចារណា...។ នៅត្រង់នេះលោកប៉ូលប្រៀបធៀបរូបកាយដែលកាន់តែចាស់ទៅៗ នឹងជីវិតខាងវិញ្ញាណដែលចេះតែចំរើនឡើងៗ។ យើងអាចបកប្រែថា« វិញ្ញាណខាងក្នុងរបស់យើង»ក៏បាន។

ឌ. អេសាយ ៤៩.៨។

ឍ. លេវីវិន័យ ២៦.១១-១២។

ណ. ២សាមូអែល ៧.១៤។

ត. លោកប៉ូលប្រើពាក្យនេះសំដៅទៅលើគ្រីស្តបរិស័ទនៅស្រុកយូដាដែលកំពុងតែខ្វះខាត ជាពិសេស បងប្អូនក្រុងយេរូសាឡឹម។

ថ. សេរីភាព (និក្ខមនំ) ១៦.១៨។

ទ. សូមអានសេចក្តីពន្យល់នៅ ២កូរិនថូស ៨.៤។

ធ. ទំនុកតម្កើង ១១២.៩។

ន. អេសាយ ៥៥.១០។

ប. «កំពែងបន្ទាយនានា» ជានិមិត្តរូបនៃអំនួតរបស់មនុស្សដែលយកខ្លួនឯងជាទីពឹង។

ផ. ឃ្លាដើម «គាត់ទន់ខ្សោយគួរឲ្យមើលងាយ»។

ព. ឃ្លានេះមានន័យស្របនឹងពាក្យខ្មែរថា «អង្គុយលើចង្អេរលើកខ្លួនឯង»។

ភ. យេរេមី ៩.២៣; ១កូរិនថូស ១.៣១។

ម. ក្នុងគម្ពីរសម្ពន្ធមេត្រីចាស់មានចែងថា ព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់ជនជាតិអ៊ីស្រាអែលយ៉ាងខ្លាំង ប្រៀបបីដូចជាស្វាមីស្រឡាញ់ភរិយា។ កាលណាជនជាតិអ៊ីស្រាអែលចេះតែក្បត់ចិត្តព្រះអង្គបែរទៅគោរពថ្វាយបង្គំព្រះឯទៀតៗ នោះគម្ពីរចែងថាព្រះអង្គមានព្រះហឫទ័យប្រច័ណ្ឌ ដូចស្វាមីឃើញភរិយាទៅមានសហាយ។ លោកប៉ូលប្រើពាក្យ «ប្រច័ណ្ឌ»នេះ បញ្ជាក់ពីសន្តានចិត្តស្រឡាញ់របស់គាត់ចំពោះគ្រីស្តបរិស័ទនៅក្រុងកូរិនថូសខ្លះដែលបែរទៅជឿតាមការប្រៀនប្រដៅរបស់គ្រីស្តទូតក្លែងក្លាយ។

យ. ពាក្យដើម សែសិបរំពាត់ខ្វះ។ តាមច្បាប់ដែលមានចែងទុកក្នុងគម្ពីរលេវីវិន័យ (២៥.៣) គេអាចធ្វើទារុណកម្មអ្នកទោសបានត្រឹមត្រូវវាយសែសិបរំពាត់ប៉ុណ្ណោះ។ ដូច្នេះ ជនជាតិអ៊ីស្រាអែលវាយអ្នកទោសសាមសិបប្រាំបួនរំពាត់ ដើម្បីកុំឲ្យលើស។

រ. សូមអានកិច្ចការ ៩.២៤-២៥។

ល. សាសន៍យូដាជឿថាមានស្ថានសួគ៌ពីប្រាំទៅដប់ជាន់។

វ. ពាក្យដើមៈក្រៅរូបកាយ។

ស. សំដៅទៅលើជម្ងឺរបស់លោកប៉ូលៈឬមួយមកពីលោកងងឹតភ្នែក ឬមានសុខភាពមិនល្អ។

ហ. ពាក្យដើម«ព្រលឹង»។

ឡ. ទុតិយកថា ១៩.១៥ ម៉ាថាយ ១៨.១៦។

អ. ពាក្យដើម «មិនបានសំរេច»។

ក. ឬ«បងប្អូនមិនដឹងថាយើងមិនមែនគ្មានព្រះអង្គគង់ជាមួយនោះទេ»។

ខ. សូមអានសេចក្តីពន្យល់នៅ ១កូរិនថូស ១៦.២០។